សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យ វិទ្យាសាស្ត្រជលផល

# សរីរៈវិទ្យាត្រី

# FISH PHYSIOLOGY

សុត វិឆន់

ឧបត្ថម្ភដោយ

CAMBODIA
RESEARCH CREATIVITY INNOVATION

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យ វិទ្យាសាស្ត្រជលផល

# សរីរៈវិទ្យាត្រី

## FISH PHYSIOLOGY

សុត វិធន់

២០២១

# រក្សាសិទ្ធ

© ឆ្នាំ ២០២១

## រក្សាសិទ្ធគ្រប់យ៉ាង

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាត ជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន (ន.គ.ស) និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា។

## ទំនាក់ទំនងព័ត៌មាន:

អ្នកនិពន្ធ៖ លោក សុត វិធន់

ទូរស័ព្ទ៖ (+៨៥៥) ៩៨ ៦៨០ ០២៣

អ៊ីមែល៖ svithun@rua.edu.kh

©. 2021 by Soth Vithun, Msc, All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition

Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sport, the Kingdom of Cambodia

Enquiries about the book:
Author: Mr. Soth Vithun

Mobile phone: (+855) 98 680 023

Email: svithun@rua.edu.kh

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្ដប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្ដល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្ដាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមាន សហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សុំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា “មូលនិធិ ស.គ.ន.” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21$^{st}$ Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

## សេចក្ដីបញ្ជាក់
## នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្ដល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# សេចក្តីថ្លែងអំណរគុណ

ទូលបង្គំ **សុត ទិចន់**

**សូមក្រាបថ្វាយបង្គំ**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

សូមថ្លែងព្រះអំណរព្រះករុណាទិគុណ សម្តេចជាអង្គម្ចាស់ជីវិតលើត្បូង ដែលបានបំពេញព្រះរាជបេសកកម្មបង្រួបបង្រួមជាតិ ប្រទានសន្តិភាពដល់ប្រទេសជាតិ កូនចៅ ជាពិសេសប្រទានឱកាសដល់កូនចៅ និង ទូលបង្គំបានសិក្សា ការចូលរួមការងារ ការចងក្រងសៀវភៅបច្ចេកទេសរហូតទទួលបានសម្រេចជោគជ័យ។ ទូលបង្គំសូមថ្វាយព្រះពរ សូមព្រះអង្គទ្រង់ព្រះចម្រើនព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងអប់រំ យុវជននិងកីឡា
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- មហាវិទ្យាល័យវិទ្យាសាស្ត្រជលផល

ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពលើយើងខ្ញុំ បានរៀនសូត្រក្រេបជញ្ជក់នូវចំណេះដឹងនិងចំណេះធ្វើផ្នែកវិទ្យាសាស្ត្រទាំងឡាយព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងសិក្សាស្រាវជ្រាវចងក្រងសៀវភៅបច្ចេកទេស រហូតទទួលបានជោគជ័យជាស្ថាពរ។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ង៉ោ ប៊ុនថាន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តម សាន វឌ្ឍនា អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា
- អង្គភាពក ដែលបានជ.ក.វ.ស្ថាប័ននានា ក្រៅពីស/ួយជ្រុមជ្រែងក្នុងការស្រាវជ្រាវ

– អ្នកផ្តល់យោបល់ ក៏ដូចជាអ្នកផ្តល់ឯកសារយោង

– គណៈកម្មការត្រួតពិនិត្យ

– ក្រុមគ្រួសារអ្នកនិពន្ធ ។ល។

ដែលបានអនុញ្ញាតនិងផ្តល់លទ្ធភាពលើយើងខ្ញុំទាំង ២នាក់ ដោយបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ដំណើការសម្របសម្រួល ការស្រាវជ្រាវ ការប្រមូលឯកសារ ផ្តល់ពត៌មាន ដាស់តឿនអប់រំគ្រប់បែបយ៉ាងនិងបានជួយពិនិត្យណែនាំចង្អុលបង្ហាញផ្លូវក្នុងការចងក្រងនូវសៀវភៅបច្ចេកទេសនេះ ប្រព្រឹត្តទៅដល់ទីបញ្ចប់ប្រកបដោយជោគជ័យ។

## យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកត្តញ្ញូបំផុតចំពោះ

អ្នកម្តាយ លោកឪពុក អ៊ុំប្រុស អ៊ុំស្រី លោកពូ អ្នកមីង ព្រមទាំងបងប្អូន ញាតិមិត្ត លោកគ្រូ អ្នកគ្រូ ដែលបានចូលរួមតាំងពីដើមរហូតរៀងមកដោយះ ចិញ្ចឹមបីបាច់ថែរក្សា ខិតខំផ្តល់ចំណេះដឹង ដំបូន្មាននិងបទពិសោធន៍ការងារ បង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ក៏ដូចជាគាំទ្រទំនុកបម្រុងក្នុងការសិក្សាស្រាវជ្រាវឯកសារពាក់ពន្ធ័ បច្ចេកទេសជំនាញជលផល ព្រមទាំងលើកទឹកចិត្ត រហូតសំរេចបានបំណង ចងក្រងជាសៀវភៅបច្ចេកទេសនេះ។

យើងខ្ញុំ សូមថ្លែងអំណរគុណ ចំពោះមិត្តភក្រ្តិទាំងឡាយដែលបានជួយផ្តល់ជាគំនិតយោបល់និងកម្លាំងចិត្តជំរុញក្នុងកិច្ចការចងក្រងសៀវភៅជាលើកដំបូងនេះឡើង។

# អារម្ភកថា

សរីរៈវិទ្យាត្រី ជាមុខវិជ្ជាមូលដ្ឋានមួយក្នុងចំណោមមុខវិជ្ជាដ៏ទៃផ្សេងទៀតក្នុងវិស័យជលផល ការបញ្ចូលមុខវិជ្ជានេះក្នុងកម្មវិធីសិក្សានៅ មហាវិទ្យាល័យវិទ្យាសាស្ត្រជលផលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្នុងគោលបំណងផ្តល់ចំណេះដឹងអំពីពីប្រព័ន្ធរំលាយអាហារ និង ការបញ្ចេញចោល ដើម្បីឱ្យដឹងពីតម្រូវការសាជាតុចិញ្ចឹមសម្រាប់ត្រី និងពីដំណាកដង្ហើមរបស់ត្រីដើម្បីឱ្យដឹងពីសមត្ថភាពភាពធន់នឹងភាពងាយរងគ្រោះដោយកត្តាបរិស្ថាន ផ្សេងៗ ហើយថែមទាំងដឹងដំណើរការបន្តពូជ ដើម្បី ឱ្យដឹងពីវដ្តវកាលពងកូន ការលូតលាស់ត្រីចូលរួមក្នុងការបង្កើននៅផលិតកម្មស្បៀងតាមរយៈវារីវប្បកម្មផងដែរ ។

ដើម្បីឆ្លើយតបតាមគោលបំណងខាងលើ យើងខ្ញុំបានរៀបចំចងក្រងចំណេះដឹងទាំងនេះឡើងជាលើកដំបូង ដូច្នេះប្រាកដជាមានការខ្វះខាតជាមិនខាន សង្ឃឹមមិត្តអ្នកអាន អ្នកបច្ចេកទេស អ្នកមានពុទ្ធិ សិស្ស និស្សិត នឹងជួយកែលម្អ និងផ្តល់នូវចំណុចវិជ្ជមានឬអវិជ្ជមាន ព្រមទាំងការអព្យាស្រ័យ។

យើងខ្ញុំសូមជូនពរមិត្តអ្នកអានជួបតែសុខចម្រើននិងសម្រេចដូចបំណងប្រាថ្នា៕

ថ្ងៃ ព្រហស្បតិ៍ ៣ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ពស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា គស. ២០២១

**អ្នកនិពន្ធ**

**សុត ទិធន់**

# អ្នកនិពន្ធ




នាម និងគោត្តនាម ៖ សុត វិធន់

អាស័យដ្ឋាន ៖ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ

ស្ថាប័នការងារ ៖ សាកលវិទ្យាល័យភូមិន្ទកសិកម្ម


ឯកទេស ឬមុខជំនាញ ៖ វិទ្យាសាស្ត្រជលផល

ប្រវត្តិការសិក្សា ៖ បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជលផល ឆ្នាំ២០១៣
អនុបណ្ឌិតផ្នែកគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ២០១៦

បទពិសោធន៍ការងារ ៖ ធ្វើការក្នុងជំនាញជលផលរយៈពេល១១ឆ្នាំ

# មាតិកា

**ទំព័រ**


បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

សេចក្តីថ្លែងអំណរគុណ ............ i

អារម្ភកថា ............ iii

បញ្ជីមាតិការ ............ v

បញ្ជីពាក្យសរសេរកាត់ ............ xi

**មេរៀនទី១ លក្ខណៈទូទៅនៃសរីរវិទ្យាត្រី**

១ លក្ខណៈទូទៅ. ............ ០១

១១. ទិសដៅ និងសារៈសំខាន់នៃសរីរវិទ្យាត្រី ............ ០១

១.២ តួនាទីនៃសរីរវិទ្យាត្រី ............ ០១

២. លក្ខណៈនៃភាវរស់ ............ ០៤

២.១ បម្លែងសារជាតុ ............ ០៤

២.២ លក្ខណៈរំញោច ............ ០៤

២.៣ ភាពបន្សុំ ............ ០៤

៣. Harmonize មុខងារក្នុងសរីរាង្គ ............ ០៥

៣.១ Harmonize មុខងារនៃ Humour ............ ០៥

៣ ២.Harmonize មុខងារនៃប្រព័ន្ធវិញ្ញាណ ............ ០៦

**មេរៀនទី២ សរីរប្រព័ន្ធសរីរាង្គត្រី**

១. សរីរសរីរាង្គក្រៅត្រី ............ ០៧

១.១ ទម្រង់រូបរាង្គត្រី ............ ០៧

២.សរីរសរីរាង្គគ្រោងឆ្អឹង ............ ៣៩

២១. មជ្ឈដ្ឋានរស់នៅ ............ ៣៩

២ជម្រករស់នៅ ១. ............ ៣៩

២ប្រភេទជម្រកធម្មជាតិ ២. ............ ៣៩

៣.ការធ្វើចរាចរ ............ ៣៩

## មេរៀនទី៣ សរីរសាស្ត្រ ឈាម


១. សញ្ញាណ ........ ៤១

១អត្ថន័យសារជាតិនៅក្នុង និងក្រៅកោសិកា ១. ........ ៤១

១ ២.អត្ថន័យរួមនៃឈាម ........ ៤១

២. មុខងារនៃឈាម ........ ៤១

២.១ មុខងារដឹកនាំ ........ ៤១

២.២ មុខងារកែសម្រួលសារជាតុចិញ្ចឹម ........ ៤២

២.៣ មុខងារបម្លែងសារជាតុសរីរាង្គ ........ ៤២

២.៤មុខងាការពារ ........ ៤២

៣. បរិមាណឈាម ........ ៤២

៣.១ វិធីសាស្ត្រវាស់មាឌរបស់ប្លាស្មា ........ ៤២

៤. សមាសភាពគីមី និង លក្ខណៈរូប-គីមីនៃឈាម ........ ៤៣

៤.១ សមាសភាពគីមីនៃឈាម ........ ៤៣

៤.២ លក្ខណៈរូបគីមី នៃឈាម ........ ៤៥

៥. សមាសភាពកោសិកាឈាម ........ ៤៧

៥ ១.Erythrocyte ........ ៤៣

៥ ២.Leukocyte ........ ៥២

៥.៣ Thrombocyte ឬ Platelest ........ ៥៤

៦. Mechanism កកឈាម ........ ៥៤

៧.បេះដូង ........ ៥៥


## មេរៀនទី៤ សរីរាង្គដកដង្ហើមនិងផ្លោកខ្យល់


១.មជ្ឈដ្ឋានដកដង្ហើម និងសញ្ញាណ ........ ៦២

១.១ មជ្ឈដ្ឋានដកដង្ហើម ........ ៦២

១.២ សញ្ញាណមួយចំនួន ........ ៦៣

២.មេការនិចដកដង្ហើម ........ ៦៣

២.១ ចលនាមេកានិចនៃការដកដង្ហើមដោយស្រកី និងបាតុភូតខ្ពុលលាង ........ ៦៣

២.១ ការដឹកនាំខ្យល់ដោយ Hb ........ ៦៤

២.៣ ការផ្លាស់ប្តូរខ្យល់ ទឹក និងឈាមនៅស្រកី ........ ៦៨

២.៤ ការផ្លាស់ប្តូរខ្យល់ រវាងឈាម និងចំណាត់តាំងជាលិការ ......... ៦៩
២.៥ Frequency ដកដង្ហើម ......... ៦៩
២.៦ កម្រិតប្រើប្រាស់អុកស៊ីសែន ......... ៦៩
៣.កត្តាមានឥទ្ធិពលដល់ការដកដង្ហើម ......... ៧០
៣.១ សីតុណ្ហភាព ......... ៧០
៣.២ អុកស៊ីសែន និង កាបូនឌីអុកស៊ីត ......... ៧០
៣.៣ ការដកដង្ហើមពេលធ្វើចលនា ......... ៧១
៣.៤ ឥទ្ធិពលជាតិពុលគីមី ......... ៧១
៤.ការដកដង្ហើមដោយប្រព័ន្ធដកដង្ហើមរង ......... ៧១
៤.១ ការដកដង្ហើមដោយពោះវៀន ......... ៧២
៤.២ ការដកដង្ហើមដោយស្បែក ......... ៧២
៤.៣ ការដកដង្ហើមដោយសរីរាង្គលើស្រកី ......... ៧៣
៤.៤ ការដកដង្ហើមដោយសួត ......... ៧៣
៥.ទម្រង់របស់ប្លោកខ្យល់ ......... ៧៣
៥.១ ប្លោកខ្យល់បើក ......... ៧៤
៥.២ ប្លោកខ្យល់បិទ ......... ៧៤
៦.មុខងាររបស់ ប្លោកខ្យល់ ......... ៧៤
៦.១ មុខងារ Hydrostatics ......... ៧៤
៦.២ មុខងារដកដង្ហើម ......... ៧៦
៦.៣ មុខងារទទួលអារម្មណ៍ ......... ៧៦
៦.៤ មុខងារបញ្ចេញសូរសំឡេង ......... ៧៧

**មេរៀនទី៥ សរីររំលាយអាហារនិងការស្រូបយកសារធាតុចិញ្ចឹម**

១.ផ្នែករំលាយអាហារ ......... ៧៨
១.១ ប្រព័ន្ធរំលាយអាហារ ......... ៧៨
១.២ ការរំលាយអាហារ ......... ៨០
២.ផ្នែកស្រូបយកសារជាតុចិញ្ចឹម ......... ៨៤
២.១ ប្រព័ន្ធផ្លូវស្រូបយកសារជាតុចិញ្ចឹម ......... ៨៤
២.២ កន្លែងស្រូបយកសារជាតុចិញ្ចឹម ......... ៨៤

២.៣ ការស្រូបយកសាជាតុចិញ្ចឹម ........................................ ៨៥
២.៤ បណ្តាកត្តាដែលមានឥទ្ធិពលដល់ការរំលាយអាហារ ........................ ៨៦

**មេរៀនទី៦ សរីរបម្លែងសារធាតុនិងថាមពល**

១.ការបម្លែងសារជាតុ ........................................ ៨៨
១.១ បម្លែង ប្រូទីត ........................................ ៨៨
១ .៣ បម្លែងសាជាតុស្ករ ........................................ ៩២
១.៤ បម្លែងអំបិល និងទឹក ........................................ ៩២
១.៥ មុខងា vitamin ជាមួយសរីរាង្គ ........................................ ៩៣
២. ថាមពល ........................................ ៩៣
២.១ តម្លៃថាមពលនៃសារជាតុចិញ្ចឹម ........................................ ៩៤
២.២ របៀបគិតមេគុណជកដង្ហើម ........................................ ៩៥
៣. កត្តាមានឥទ្ធិពលដល់ការបម្លែងសារជាតុរបស់ត្រី ........................................ ៥៥
៣.១ កត្តាផ្ទៃកក្នុង ........................................ ៩៥

**មេរៀនទី៧ សរីរ តម្រងនោម និងការបញ្ចេញចោល**

១ .មុខងារបញ្ចេញទឹកមូតនៃតម្រងនោម ........................................ ៩៩
១ ១.Mechanism កកើតទឹកមូត ........................................ ៩៩
១.២ ការបញ្ចេញទឹកនោមនៃត្រី ........................................ ១០០
១.៣ ការបញ្ចេញទឹកនោមនៃត្រី ........................................ ១០០
២.Harmonize សម្ពាធអូស្មូស នៃត្រី ........................................ ១០២
២.១ ត្រីទឹកសាប ........................................ ១០២
២.២ ត្រីផ្អឹងទន់ទឹកប្រៃ ........................................ ១០២
២.៣ ត្រីផ្អឹងរឹងទឹកប្រៃ ........................................ ១០២
៣. កត្តាមានឥទ្ធិពលដល់ Harmonize សម្ពាធអូស្មូសនៃត្រី ........................................ ១០៣
៣.១ សីតុណ្ហភាព ........................................ ១០៣
៣.២ ការបន្តពូជ ........................................ ១០៣
៣.៣ ពេលឃ្លាន ........................................ ១០៣

## មេរៀនទី ៨ អង់ដូគ្រីនគ្លែន

១ .Thyroid gland ........ ១២១
១.១ សញ្ញាណ ........ ១២១
១.២ អំពើរអម៉ូន ........ ១២១
១.៣ អំពើរអម៉ូន Thyroid gland របស់ត្រី ........ ១២២
១.៤ Harmonize សកម្មភាព ........ ១២២
២ .Adreno Cortico Streroid( Tuyen thu than ) ........ ១២៣
២.១ អំពើរអម៉ូន Adreno Cortico Streroid ........ ១២៤
២.២ ឥទ្ធិពលនៃអម៉ូន Adreno Cortico Streroid ........ ១២៤
៣.ក្រពេញបន្តពូជ ........ ១២៤
៣.១ Endocrtise gland បន្តពូជឈ្មោល ........ ១២៤
៣.២ Endrocrise gland បន្តពូជញី ........ ១២៥
៤ .អុីប៉ូភីស( pituitary gland ) ........ ១២៥
៤.១ សញ្ញាណ ........ ១២៥
៤.២ អុីប៉ូភីស ........ ១២៥

## មេរៀនទី៩ សរីរបន្តពូជ

១.អាយុកាលបន្តពូជ ឬការបញ្ចេញចំណាស់កោសិកាបន្តពូជ ........ ១២៨
២.សមាសភាពគីមីរបស់កោសិកាបន្តពូជ ........ ១២៨
៣ .ការប្រែប្រួលកោសិកាបន្តពូជ និងសរីរាង្គត្រីក្នុងដំណើរការពេញចំណាស់កោសិកាបន្តពូជ.... ........ ១២៩
៣.១ លក្ខណៈសរីរាង្គរបស់ស្ពៃម ........ ១២៩
៣.២ ការពារពេញចំណាស់របស់កោសិកាពងត្រី ........ ១៣០
៣.៣ ការផ្លាស់ប្តូរលក្ខណៈសរីរៈ និងដំណើរការគីមីក្នុងដំណាក់កាលពេញចំណាស់ និងការបញ្ចេញពងឬស្ពៃម ........ ១៣១
៤.ឥទ្ធិពលដំណើរការរបស់ Hormone បន្តពូជ ........ ១៣២
៥.ការបង្កកំណើត និងចលនាការញាស់ ........ ១៣៣
៥.១ ការបង្កកំណើត ........ ១៣៣
៥.២ ចលនានៃការញាស់ ........ ១៣៤

៦.បណ្តាកត្តាផ្ទៃក្រៅមានឥទ្ធិពលដល់ដំណើរការបន្តពូជរបស់ត្រី ........ ១៣៥
៦.១ សារធាតុចិញ្ចឹម ........ ១៣៥
៦.២ សីតុណ្ហភាព ........ ១៣៦
៦.៣ ពន្លឺ ........ ១៣៦
៦.៤ ចរន្តទឹក ........ ១៣៦

**បណ្ណាល័យសាស្ត្រ**

**ឧបសម្ព័ន្ធ**

# បញ្ជីពាក្យសរសេរកាត់

| ពាក្យសរសេរកាត់ | | ការពន្យល់ |
| --- | --- | --- |
| សម | ៖ | សង់ទីម៉ែត្រ |
| ឧទា. | ៖ | ឧទាហរណ៍ |
| % | ៖ | ភាគរយ |
| pH | ៖ | អ៊ីដ្រូសែនអ៊ីដ្រូសែន |
| $mm^3$ | ៖ | មីលីម៉ែត្រ គូប |
| Gr | ៖ | ក្រាម |

# មេរៀនទី១
# លក្ខណៈទូទៅនៃសរីរវិជ្ជាត្រី

## ១.លក្ខណៈទូទៅ

ត្រី ជាសត្វអថេរកំដៅ( Poikilothemic )មានឆ្អឹងកងរស់នៅក្នុងទឹក ដកដង្ហើមតាមស្រកី និងបំលាស់ទីដោយព្រុយ។ គេរាប់បញ្ចូលវានៅក្នុងក្រុមសត្វឆ្អឹងកងចាស់ជាងគេ ដែលមានប្រភពពីបុព្វមានពួរឆ្អឹងខ្នង (chordate) នៃសម័យកាលអំប្រីយ៉ុង (Cambrian) រឺអាចមុខសម័យកាលនេះទៅទៀតដែលគេមិនធ្លាប់ស្គាល់។ មានត្រីបួនថ្នាក់ដែលត្រូវបានគេស្គាល់។ ត្រីជាន់ដើមជាងគេ គឺត្រីគ្មានថ្គាម Myxinoides (haglish) និងឡំព័រ (Lampreys )។ វាមានទម្រង់សារពាង្គកាយដូចអន្ទង់ គ្មានព្រួយគូ គ្រោងឆ្អឹងជាឆ្អឹងខ្ចី និងមានពួរប្រសាទពេញមួយជីវិតរបស់វា ព្រមទាំងមានមាត់ដូចថាស បណ្តុំទៅនឹងការជប់ឬខាំ។ សត្វឆ្អឹងកងផ្សេងទៀតមានថ្គាមដែលជាការលូតលាស់ដ៏សំខាន់នៃវិវត្តន៍សត្វឆ្អឹងកង និងអាចត្រូវការបានបែងចែកតទៅតាមសមាសភាពនៃគ្រោងឆ្អឹងរបស់វា...សមាជិករបស់ថ្នាក់ត្រីឆ្អឹងខ្ចី Chondrich- thyes (ឆ្លាម , បបែល, skates និង Chimaeras) មានគ្រោងឆ្អឹងជាឆ្អឹងខ្ចី ព្រុយគូ សរីរាង្គវិញ្ញាណប្រសើរនិងជាសត្វរំពា។ ថ្នាក់ត្រីទី៤រួមមានត្រីឆ្អឹង(Osteichthyes) ដែលជាក្រុមមួយដ៏ធំ និងសំបូរបែប ក្នុងនោះមានប្រភេទ Teleosts (មានន័យថាទាំងស្រុងនិងឆ្អឹងដែលតាង ឱ្យអំបូរតី ទឹកសាប និងត្រីទឹកប្រៃស្ទើរទាំងអស់)។

Teleosts បានវិវត្តទៅជា ២១ ០០០ ប្រភេទត្រីដែលបង្ហាញនូវបណ្តុំទៅនឹងបរិស្ថានសំបូរបែបរាងរៅសារពាង្គកាយ អាកប្បកិរិយា និងកន្លែងរស់នៅប្លែកៗ។ ប្រហែល ៨៤០០ប្រភេទនៃប្រភេទទាំងអស់ឬប្រហែល ២/៥ នៃប្រភេទត្រីទាំងអស់រស់នៅក្នុងទឹកសាប ប៉ុន្តែវារស់នៅស្ទើរគ្រប់ទឹកន្លែងទាំងអស់តាំងពីទឹក ទឹកកក ទឹកប្រៃនៃមហាសមុទ្រទៅដល់កន្លែងទឹករាក់ ល្បាប់ ទឹកសាបតាមវាលស្រែនៅក្នុងប្រទេសកម្ពុជា ។

យើងនឹងផ្តោតការសិក្សាទៅលើត្រីឆ្អឹង ពីព្រោះវារួមមានស្ទើរគ្រប់ប្រភេទត្រី ដែលមានប្រយោជន៍នៅកម្ពុជា។ សារពាង្គកាយត្រីមានលក្ខណៈខ្លះៗដូចសារពាង្គកាយសត្វឆ្អឹងកងដទៃទៀតដែរ។ វាមានគ្រោងឆ្អឹង នៅខាងក្នុង ស្បែកខាងក្រៅ និងមានសរីរាង្គខាងក្នុងដូចជាបេះដូង ពោះវៀន និងខួរក្បាល។ ប៉ុន្តែត្រីក៏មាន លក្ខណៈដោយឡែករបស់វាដែរ។ ស្បែកត្រីស្តើងនិងច្រើនតែគ្របដណ្តប់ដោយស្រកា ។ វាមានព្រុយជំនួស ជើង ស្រកីជំនួសសួតសម្រាប់អុកស៊ីសែនរវាងទឹកនិងឈាម។ ត្រីបង្ហាញនូវតម្រូវអូស្មូស (Osmotic និងអ៊ីយ៉ុង Ionic ) ដ៏លូតលាស់និងអាចឱ្យត្រីអណ្តែតក្នុងទឹកដោយការបំពេញឧស្ម័នក្នុងប្លោកខ្យល់ដែល ជាឧបករណ៍បញ្ចេញឧស្ម័នដ៏មានប្រសិទ្ធភាពក្នុងរដ្ឋៈសត្វ។ ត្រីមួយចំនួនមានសរីរាង្គ

បង្កើតពន្លឺ ឬអគ្គីសនី ដែលវាប្រើសម្រាប់ទាក់ទងគ្នា ឬទាក់ទាញនិងសំលាប់រំពោនៅពេលខ្លះ ។ ត្រីមានប្រព័ន្ធសរីរាង្គវិញ្ញាណខាងក្រៅហៅថាប្រព័ន្ធវិញ្ញាណចំហៀង (Lateral line system) ដែលរួសទៅនឹងលំញ័រទឹកអាចឱ្យត្រី ដឹងពីចលនានានាឆ្ងាយពីគំហើញរបស់វា ។

## ១.១ ទិសដៅ និងសារៈសំខាន់នៃសរីរវិទ្យាត្រី

**ទិសដៅ** ការសិក្សាសរីរសាស្ត្រត្រី ជាផ្នែកមួយនៃសរីរវិទ្យា ដែលសិក្សាស្រាវជ្រាវលក្ខណៈនៃដំណើរការមុខងារសរីរាង្គត្រី និងដំណើរការបណ្តូរូបធាតុរបស់សរីរាង្គជាមួយមជ្ឈដ្ឋានរស់នៅដោយទទួលឥទ្ធិពលពីគ្នាទៅវិញទៅមក (ជាសំខាន់ត្រូវយល់ច្បាស់អំពី ក្រិត្យក្រម ឬដំណើរការកកើត ការលូតលាស់ និងបម្លែងមុខងារសារពាង្គកាយភាវៈរស់)។

**សារៈសំខាន់** មិនគ្រាន់តែឱ្យយើងដឹងអំពី សកម្មភាព ក្រិត្យក្រម និងលក្ខខណ្ឌរស់នៅរបស់ត្រីជាងនេះទៅទៀតយើងអាចៈ ទប់ទល់ ប្រើប្រាស់ឥទ្ធិពលលក្ខខណ្ឌ សកម្មភាព ក្រិត្យក្រម និងលក្ខខណ្ឌរស់នៅទាំងនេះទៅតាមវិធីសាស្ត្រ និងតម្រូវការអភិវឌ្ឍន៍នៅក្នុងដំណើរការផលិតកម្មទៀតផង។

## ១.២ តួនាទីនៃសរីរវិទ្យាត្រី

–សិក្សាស្រាវជ្រាវ និងបង្ហាញបណ្តាលបាតុភូតនៃសកម្មភាពរស់នៅជាធម្មតានៃសារពាង្គកាយរបស់ត្រី

–សិក្សាស្រាវជ្រាវ និងបង្ហាញនូវសភាពលក្ខណៈនៃការប្រែប្រួលខុសពីភាពធម្មតា និងឥទ្ធិពលធ្វើឱ្យប្រែប្រួលពីសភាពធម្មតារបស់ត្រី។ ជាមុខវិជ្ជាមូលដ្ឋានឱ្យយើងក្តាប់បាន និងរៀបចំបាននូវការយល់ដឹងជាមូលដ្ឋានរួចដាក់ចេញនូវវិធីសាស្ត្រ ឬបច្ចេកទេសសមស្រប ដែលឱ្យយើងទទួលបាននូវលទ្ធផល និងទិន្នផលទៅតាមតម្រូវការប្រើប្រាស់ ដូចជាៈ

- សរីរសាស្ត្របម្លែងសារធាតុ និងដកដង្ហើម បង្កើតបានបច្ចេកកទេសក្នុងការចិញ្ចឹមការថែបំប៉ន និងការដឹកជញ្ជូនផលជលផលរស់ ការរក្សាអត្រារស់ខ្ពង់តាមតម្រូវការ។ល។
- សរីរសាស្ត្របន្តពូជ បង្កើតបានបច្ចេកទេសប្រើប្រាស់ អ័រម៉ូន រំញោចទៅលើការបង្កកំណើត ការជម្រុះពងទៅតាមពេលវេលា ឬចំនួនតម្រូវការ ការថែរក្សាស្លេមទុក ការបង្កាត់ភ្ញាស់សិប្បនិម្មត និងការចិញ្ចឹមរក្សាកោសិកាបន្តពូជ។ល។
- សរីរសាស្ត្ររំលាយអាហារ និងសារធាតុចិញ្ចឹម ឱ្យយើងបង្កើតចេញបច្ចេកទេសចិញ្ចឹមការថែបំប៉នដោយ ការផលិតចំណី ប្រើប្រាស់សារធាតុរំញោចក្នុងវារីវប្បកម្ម ដូចជា កត្តាថាមពល វីតាមីន និងថ្នាំការពារជំងឺទៅក្នុងចំណីអាហារក្នុងគោលបំណងបន្ថយរយៈពេលចិញ្ចឹម ព្រមទាំងចំណាយបរិមាណចំណីតិច បន្ថយអត្រាបាត់បង់ដោយទទួលទិន្នផល និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពង់។

## ១.៣ ទំនាក់ទំនងវិជ្ជាសរីរសាស្ត្រជាមួយវិជ្ជាដ៏ទៃទៀត

### ក/មុខវិជ្ជាកាយវិភាគវិជ្ជារបស់ត្រី

ទំនាក់ទំនងនៃស្ថានភាពទម្រង់ស្រកីនៃប្រភេទ៖ ត្រីរស់ ត្រីអណ្ដែង ត្រីដំរី ត្រីក្រាញ់ ធ្វើឱ្យយើងដឹងថា វាជកដង្ហើមយក អុកស៊ីសែន ពីបរិយាកាសបាន យើងបង្កើតបានវិធីសាស្ត្រដឹកជញ្ជូនត្រីនៅរស់ និងមានអត្រារស់ខ្ពស់។

– **មុខវិជ្ជាគីមី-ជីវ ៖** ដឹងបាននូវដំណាក់កាល និងដំណើរការប្រតិកម្មគីមីក្នុងសរីរាង្គ និង ការប្រើថាមពល ធ្វើឱ្យយើងបង្កើតបានវិធីសាស្ត្រ៖ ចិញ្ចឹម វិធីផលិតចំណី ពេលវេលាផ្ដល់ចំណី...។ល។

– **មុខវិជ្ជាសេនេទិច ៖** ដឹងបាននូវការជ្រើសរើសពូជ បង្កៃងពូជតម្រូវទៅតាមចំណង់ប្រើប្រាស់ ប្រសិទ្ធភាពពូជធន់ការប្រែប្រួលអាកាសធាតុ...។ល។

## ១.៤ វិធីសាស្ត្រស្រាវជ្រាវសរីរសាស្ត្រ

វិធីសាស្ត្រស្រាវជ្រាវសរីរសាស្ត្រចែកជាពីរវិធីសាស្ត្រ៖ វិធីសាស្ត្រវិភាគ និងវិធីសាស្ត្រសរុប។

### ក/ វិធីសាស្ត្រវិភាគ

បានអនុវត្តន៍ពីសតវត្សទី ១៦ ដល់ពាក់កណ្ដាលសតវត្សទី ១៩ ជារួមមានវិធីសាស្ត្រដើម្បីធ្វើការវិភាគ៖

- វិធីសាស្ត្រកាត់ផ្ដាច់សរីរាង្គផ្នែកណាមួយនៃសារពាង្គកាយសត្វរួចដាក់ក្នុងមជ្ឈដ្ឋានសិប្បនិមិត្ត ដោយឱ្យវាធ្វើការបម្លែងមុខងារក្នុងរយៈពេលណាមួយឆ្លងតាមលក្ខណៈនេះធ្វើការស្រាវជ្រាវសកម្មភាពសរិរសរីរាង្គ និងកត្តា ដែលមានទំនាក់ទំនងសកម្មភាពមុខងារសរីរាង្គទាំងនោះ។

- វិធីសាស្ត្រ កាយវិភាគ យករាងកាយទាំងរស់ (ប្រើថ្នាំសន្លប់ ស្ពឹក) ដើម្បី ទ្រុះត្រាយផ្នែកណាមួយនៃសរីរាង្គ ផ្នែកឈាម ប្រព័ន្ធសរសៃវិញ្ញាណ...។ល។ ជាលទ្ធផលភាវរស់មិនអាចរក្សាបាននូវ លក្ខណៈធម្មតា ឬមិនរស់នៅបន្តបាន។

លក្ខណៈប្រសើរនៃវិធិវិភាគនេះធ្វើឱ្យយើងតាមដានពិសោធន៍ដោយផ្ទាល់នូវសកម្មភាពសរីរាង្គទាំងនេះ ដែលឱ្យយើងចូលជ្រៅក្នុងការស្រាវជ្រាវលម្អិតទិសដៅសរីរៈ និងផ្លាស់ប្ដូរសរីរនៃសរីរាង្គភាវរស់។

ផលវិបាកនៃវិធីសាស្ត្រវិភាគនេះធ្វើឱ្យភាវរស់មិនស្ថិតនៅជាលក្ខណៈធម្មតាមុខងារសកម្មភាពដែលពិនិត្យ អង្កេតជាតំណាងឱ្យសកម្មភាពក្នុងរយៈពេលខ្លី ចំណេះដឹង ដែលទទួលបានមិនទូលំទូលាយ មិនអាចផ្ទៀងផ្ទាត់បានក្នុងលក្ខខណ្ឌធម្មជាតិបាន។

### ខ/ វិធីសាស្ត្រសរុប

ដោយទាញចេញលទ្ធផលខ្លះៗនៃវិធីសាស្ត្រវិភាគធ្វើឱ្យយើងប្រើវិធីយកសារពាង្គទាំងស្រុងធ្វើការសាកល្បងពិសោធន៍ក្នុងមជ្ឈដ្ឋានប្រហាក់ប្រហែលធម្មជាតិ (មជ្ឈដ្ឋានសិប្បនិមិត្ត) ដោយពិនិត្យអង្កេត

ការប្រែប្រួលសកម្មភាពរបស់វាដើម្បីបន្សាំទៅនឹងភាពប្រែប្រួលសរីរសរីរាង្គភាវរស់នឹងការផ្លាស់ប្តូរ ឬការប្រែប្រួលមជ្ឈដ្ឋាន។

ឧទាហរណ៍៖ ពិសោធន៍តាមដានដំណើរការដកដង្ហើម និងការប្រើប្រាស់អុកស៊ីសែនរបស់ត្រី។

## ២. លក្ខណៈនៃភាវរស់

### ២.១ បម្លែងសារធាតុ

ភាវរស់មិនអាចរស់នៅឯកឯងក្នុងសកម្មភាពរស់នៅឡើយ រាល់គ្រប់នាទីតែងមានឥទ្ធិពលជាមួយមជ្ឈដ្ឋានជុំវិញ ជានិច្ចកាលភាវរស់មិនអាចឈប់បណ្តូសារជាតុបង្កើតជាសារជាតុសរីរាង្គផ្ទាល់បានឡើយ និងជាប្រចាំបម្លែងបង្កើតថាមពលបម្រុងផ្ទុក បម្លែងថាមពលសម្រាប់ដំណើរការសកម្មភាពរស់នៅ លូតលាស់ធំធាត់ និងទប់ទល់មជ្ឈដ្ឋានរស់នៅផលិតផលក្រោយពេលបណ្តូសារជាតុ និងបម្លែងត្រូវបានបញ្ចេញមកក្រៅ នេះហៅថាបម្លែងសារជាតុ ដូចនេះការបម្លែងសារជាតុជាលទ្ធផលនៃសមានកម្ម និងអសមានកម្មសារជាតុសរីរាង្គ។

សមានកម្ម និងអសមានកម្ម ជាសកម្មភាព ដែលមានទំនាក់ទំនងដែលមិនអាចផ្តាច់ចេញនូវសកម្មភាពណាមួយបាន ព្រមទាំងបានឆ្លងកាត់ដំណាក់កាលប្រតិកម្មគីមីសរីរាង្គជាច្រើន និងសាំញ៉ាំ។

### ២.២ លក្ខណៈរំញោច

ក្នុងដំណើរការរស់សារជាតិ ដែលធ្វើអំពើលើសសារពាង្គកាយភាវរស់ហៅថារំញោច។ ដំណើរការរំញោចកកើតដោយកត្តាជាច្រើន ដូចជារំញោចដោយកត្តាមេកានិច គីមី និងរំញោចដោយកត្តារូប។

លក្ខណៈរំញោចមានពីរយ៉ាង គឺ រំញោចសមស្រប និងរំញោចមិនសមស្រប។

រំញោច ដែលភាវរស់ទទួលយកបានហៅថារំញោចសមស្រប និងរំញោច ដែលភាវរស់មិនអាចទទួលយកបានហៅថារំញោចមិនសមស្របដូចជា រំញោចលើកោសិកាសាច់ដុំធ្វើឱ្យញ័រ កន្ទាក់ ភ្ញាក់ រំញោចលើប្រព័ន្ធវិញ្ញាណធ្វើឱ្យ រំភើប រន្ធត់ ភ័យខ្លាច រំញោចទៅលើចំណាត់តាំងក្រពេញធ្វើឱ្យការបញ្ចេញកាកសំណល់ដូចជាពេលផឹកទឹកក្តៅញើសបញ្ចេញមក ឃើញគេញ៉ាំម្ជូរទឹកមាត់បានបញ្ចេញមក។ គ្រប់រំញោជជានិច្ចការមានដំណាក់កាលដំណើរការ ការប្រែប្រួលសារជាតុ និងបង្កើតឡើងថាមពល ឬប្រើប្រាស់ថាមពល នៅពេលការបម្លែងសារជាតុបានបញ្ឈប់សកម្មភាពនោះ លក្ខណៈរំញោចបានត្រូវបញ្ឈប់តាមដែរក្នុងករណីភាវរស់ទទួលរំញោច កកើតមានប្រតិកម្មឆ្លើយតប កំណត់ឡើងដោយសកម្មភាពក្រៅអាចមានលក្ខណៈ ២៖

– សរីរាង្គស្ងៀមស្ងាត់ទៅជាមានសកម្មភាព ពីសកម្មភាពខ្សោយទៅជាខ្លាំងក្លាហៅថា រំញោចសមស្រប

– សរីរាង្គពីសកម្មភាពខ្លាំងទៅជាសកម្មភាពខ្សោយនេះហៅថា រំញោចមិនសមស្រប។

លក្ខណៈរំញោចសមស្រប និងមិនសមស្របទាំងពីរនេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ដូចជាការប្រើ អ័រម៉ូន: HCG, Suprefact ហើយនឹង អ៊ីប៉ូភីស ឬ អ័រម៉ូនផ្សេងៗ ទៅលើការបង្កកំណើតនៃត្រីប្រភេទត្រីខ្លះអាចទទួលយក HCG, Suprefact ឬ អ៊ីប៉ូភីស ដោយជម្រុះពង ឬស្លែមបានទេ។

## ២.៣ លក្ខណៈបន្សាំ

រាល់សកម្មភាពរស់នៅរបស់ភាវរស់ ដែលអាចរក្សាបាននូវសកម្មភាពជាធម្មតា ក្នុងមជ្ឈដ្ឋានណាមួយបានមានន័យថាគ្រប់ភាវរស់នោះរក្សាបាននូវសភាពសមស្របជាមួយមជ្ឈដ្ឋានក្នុងករណីមជ្ឈដ្ឋានប្រែប្រួលភាវរស់នោះប្រែប្រួលសកម្មភាពរស់នៅបានធម្មតានោះហៅថា បន្សាំ។ បន្សាំដោយការប្រើប្រាស់រំញោចសមស្រប និងមិនសមស្រធ្វើជាមូលដ្ឋានក្នុងដំណើរការអភិវឌ្ឍន៍នៃការបម្លែងសារធាតុ និងមុខងារសរីរាង្គរបស់ភាវរស់។

## ៣. Harmonize មុខងារក្នុងសរីរាង្គ

គ្រប់ភាវរស់អាចស្ថិតថេរវិវឌ្ឍន៍លូតលាស់បានត្រូវបានបន្សាំទៅតាមមជ្ឈដ្ឋានរស់នៅជានិច្ចកាលមានការប្រែប្រួលផ្លាស់ប្តូរសារធាតុទៅតាមលក្ខខណ្ឌប្រែប្រួលនៃមជ្ឈដ្ឋានរស់នៅនេះហៅថាសកម្មភាព **Harmonize** មុខងារនៃសរីរាង្គក្នុងករណី ដែលភាវរស់មិនអាចប្រែប្រួលផ្លាស់ប្តូរសារធាតុទៅតាមស្ថានភាព ទិដ្ឋភាព និងលទ្ធភាពនៃមជ្ឈដ្ឋានបាន នោះភាវរស់នោះត្រូវវិនាសបាត់។

Harmonize គឺជាការដឹកនាំ ការសម្របសម្រួល ការចាត់ចែង ការបម្លែងសារធាតុមួយ ច្រើន ឬទាំងស្រុងនៃសរីរាង្គ ដើម្បីធ្វើការលូតលាស់វិវឌ្ឍន៍ និងបន្សាំទៅនឹងទិដ្ឋភាព លទ្ធភាពមជ្ឈដ្ឋានបាន។

សកម្មភាព Harmonize មាន២៖ Harmonize មុខងារនៃ Humour និង Harmonize មុខងារនៃប្រព័ន្ធវិញ្ញាណ។ សកម្មភាព Harmonize រួមមាន ការដឹកនាំ ការសម្របសម្រួល ចាត់ចែង បម្លែងសកម្មភាពន័យបង្គុំប្រព័ន្ធអង់ស៊ីម និងប្រព័ន្ធវិញ្ញាណ។

### ៣.១ Harmonize មុខងារនៃ Humour (សារធាតុមានលក្ខណៈរាវនៅក្នុងនិងក្រៅកោសិកា ឬអង់ស៊ីម)

Harmonize មុខងារនៃបង្គុំប្រព័ន្ធអង់ស៊ីមដោយដំណើរ ដឹកនាំ សម្របសម្រួល ចាត់ចែង បម្លែងសកម្មភាពសារធាតុនៅក្នុង និងក្រៅកោសិកាដោយពឹងផ្អែកទៅលើបង្គុំប្រព័ន្ធអង់ស៊ីម (Humour) ដឹកនាំសម្របសម្រួលចាត់ចែងសកម្មភាព និងមានអំពើដោយផ្ទាល់ជាមួយសកម្មភាពរស់។ ដំណាក់កាលនេះត្រូវឆ្លងកាត់ដំណាក់កាលបម្លែង ការប្រែប្រួលផ្លាស់ប្តូរផ្នែកគីមីសរីរាង្គអំពើទាំងនេះមានឥទ្ធិពលសកម្មភាព និងលទ្ធភាពនៃការបង្កើតអង់ស៊ីម (Humour) ។

## ៣.២ Harmonize មុខងារនៃប្រព័ន្ធវិញ្ញាណ

សកម្មភាព Harmonize នៃHumour មិនអាចគ្រប់គ្រាន់ និងមានប្រសិទ្ធភាពខ្លាំងក្លាទៅតាមតម្រូវការ និងទាន់ពេលវេលាដើម្បីទប់ទល់ទៅនឹងមជ្ឈដ្ឋាន និងការវិវឌ្ឍន៍លូតលាស់នោះត្រូវមានការចូលរួម នៃប្រព័ន្ធវិញ្ញាណ។

ដូច្នេះដំណើរ Harmonizeទាំងពីរមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ក្នុងដំណើរការនេះប្រព័ន្ធវិញ្ញាណ គឺជា កត្តាកំណត់យ៉ាងសំខាន់ក្នុង Harmonize មុខងារនៃសរីរាង្គ។




រូបភាព ១.១ Harmonize

# មេរៀនទី២

# សរីរប្រព័ន្ធសរីរាង្គត្រី

## ១. សរីរសរីរាង្គក្រៅត្រី

### ១.១ ទម្រង់រូបរាងត្រី

#### ក/ ការបែងចែកសរីរាង្គត្រី




រូបភាព ១.២ សរីរាង្គរបស់ត្រី

❖ ប្រភេទស្រកាត្រី

ត្រីមានថ្គាមភាគច្រើន ) Jawed fish) មានស្រកាការពារសារពាង្គកាយ។ ត្រីឆ្អឹងមានស្រកាស្តើងជាតិឆ្អឹងដែលមានគែមរាងមូល។ ស្រកានៃត្រីឆ្អឹងមាន ២ប្រភេទធំៗ គឺស្រកា Ctenoid និងស្រកា Cycloid។ ស្រកាCtenoidមានចំនុចតូចៗនៅលើស្រកា។ ត្រីដែលមានស្រកាប្រភេទនេះ ស្ទាបទៅគឺ ដូចជាត្រីចំពុះទា ) Bass) និងត្រីក្រាញ់ ) Perch)។ ស្រកា Cycloid មានផ្ទៃរលោង។ ស្រកាប្រភេទនេះ យើងប្រទះឃើញ ចំពោះត្រីគល់រាំង ) Carp) និងត្រីសូម៉ុង ) Salmon) ជាដើម។




រូបភាព ១.៣ ទម្រង់ស្រការត្រី

ស្រកាត្រីមានមុខងារជាសរីរាង្គការពារ។ ប្រភេទស្រកាត្រីរួមមាន៖ ស្តេណូអ៊ីត ស៊ីក្លូអ៊ីត និង ផ្លាកូអ៊ីត។ ស្រការលើបតូអ៊ីត មានការប្រែក្លាយជា២ប្រភេទស្រកា៖ ស៊ីក្លូអ៊ីត និងស្តេណូអ៊ីត។

❖ សរីរាង្គព្រុយត្រីនិងមុខងារ

ព្រុយត្រីមានមុខងារផ្សេងៗទៅតាមប្រភេទដូចជា៖ ព្រុយខ្នង ព្រុយកន្ទុយ ព្រុយគូត ព្រុយពោះ ព្រុយចំហៀង។ ចំណែកមុខងារនៃព្រុយដូចជា៖ ចលនា រក្សាលំនឹង និងងៀករ៉េ ឬបត់បែន។ ព្រុយ គឺជាទម្រង់ធ្វើចលនាបាន ដែលជួយឱ្យត្រីហែលនិងរក្សាលំនឹងរបស់វា។ ព្រុយត្រីធ្វើចលនា ដោយសារសាច់ដុំ។ លើកលែងប្រភេទត្រីមួយចំនួនតូចដែលមិនសូវមានលុយ ត្រីឆ្អឹងបច្ចុប្បន្នទាំងអស់មានព្រុយកាំ ) rayed fins) ដែលរួមមានបន្ទះស្បែកទ្រទ្រង់ដោយគ្រោងឆ្អឹងបណ្តោយហៅថាឆ្អឹងកាំ ) rays)។ ត្រីមួយចំនួនមានឆ្អឹងកាំទន់ ) soft rays)។ ប្រភេទផ្សេងទៀតមានទាំងឆ្អឹងកាំទន់ ទាំងឆ្អឹងកាំបន្លា )spiny rays) ដែលរឹងហើយមុត ។

ត្រី Teleosts ជាច្រើនមានព្រុយប្រកបដោយប្រសិទ្ធភាពខ្ពស់ដែលជួយឱ្យវាទៅជាអ្នកហែលមួយដ៏ចំណាន។ ត្រី Teleosts ជាច្រើនដែលរស់នៅតាមចន្លោះផ្កាថ្ម គឺជាអ្នកជំនាញខាងហែលចេញចូល តាមប្រលោះផ្កាថ្ម ។ ប៉ុន្តែត្រីឆ្អឹងមួយចំនួនទៀតហែលយ៉ាងពិបាក។ ត្រីរាងដូចអន្ទង់ខ្លះមានព្រុយមិនលូតលាស់និងជាអ្នកដែលខ្សោយ។ វារស់នៅក្នុងភក់បាតទឹក និងស្ថិតនៅទីនោះជាទូទៅ ត្រីTeleosts ជាច្រើនមានព្រុយបណ្តុំទៅនឹងចលនាខ្លះទៀតផ្សេងពីការហែល។ ឧទាហរណ៍៖ ត្រីហោះ ) flying fish) មានព្រុយដូចស្លាបដែលជួយឱ្យវាហើរសំកាំងលើផ្ទៃទឹកបាន។ ត្រី mudskipper មានព្រុយប្រកប ដោយសាច់ដុំមាំដែលអាចឱ្យវាលោតលើគោកបាន ។

ព្រុយត្រីត្រូវបានបែងចែកទៅតាមទីតាំងលើសារពាង្គកាយព្រមទាំងទៅតាមទម្រង់របស់វា។តាមរបៀបនេះ មានព្រុយសេសនិងព្រុយគូ។

ព្រុយសេស ) Median fin) ជាព្រុយបញ្ឈរនៅលើខ្នង នៅខាងពោះឬកន្ទុយ។ ព្រុយសេសរួមមាន ព្រួយខ្នង ព្រួយគូទ និងព្រុយកន្ទុយ។ ព្រួយខ្នងដុះតាមបណ្តោយខ្នង និងជួយឱ្យត្រីរក្សាជំហរត្រង់បាន។ ត្រីស្ទើរទាំងអស់មានព្រុយខ្នងមួយ ហែយីមួយចំនួនមានព្រួយខ្នងពីរឬបី។ ព្រុយគូទដុះលើផ្នែកខាងក្រោមជិត កន្ទុយ។ ដូចព្រួយខ្នងដែរ ព្រួយគូទជួយូឱ្យត្រីរក្សាជំហរត្រង់ដែរ ។ ត្រីខ្លះមានព្រុយគូទពីរ។ ព្រុយ កន្ទុយស្ថិតនៅចុងកន្ទុយ។ ត្រីរលាស់ព្រុយកន្ទុយរបស់វាពីម្ខាងទៅម្ខាងរុញខ្លួនវាទៅមុខ និងមានមុខងារជា ចង្កូត។

ព្រុយគូ ) Paired fins) ជាព្រុយពីរដូចគ្នាស្ថិតនៅសងខាងខ្លួនត្រី។ ត្រីភាគច្រើនមានព្រុយទាំងពីរយ៉ាង គឺព្រុយទ្រូង ) Pectoral fin) និងព្រុយពោះ ) Pelvic fin) ។ ព្រុយទ្រូងនៃត្រីភាគច្រើនដុះនៅផ្នែកចំហៀងខាងក្រោយក្បាល។ ត្រីភាគច្រើនមានព្រុយពោះឬជើងរបស់វានៅខាងក្រោម និងក្រោយ

ព្រុយទ្រូងបន្តិច។ ប៉ុន្តែត្រីខ្លះមានព្រុយពោះស្ថិតនៅឆ្ងាយពីបំពង់ក ឬក្បែរព្រុយកន្ទុយ។ ត្រីភាគច្រើនប្រើប្រាស់ព្រុយរបស់វាដើម្បីបត់) ប្តូរទិស( ឈប់ និងធ្វើចលនាផ្សេងទៀត ។

### ខ/ ប្រព័ន្ធវិញ្ញាណនិងមុខងារ

❖ ភ្នែក

ភ្នែកត្រីមានភ្នាសការពារទឹក ឡង់ទីមិនអាចពង្រីក ដោយអីរីស មិនអាចបើកពង្រីក ដូចនេះការមើលដោយភ្នែករបស់ត្រីមិនអាចមើលរូបភាពច្បាស់បាន ជាពិសេសរូបភាពត្រូវឆ្លងកាត់ឡង់ទីផ្ទៃទឹកទៀត ធ្វើឱ្យរូបភាពកាន់តែឃ្លាតឆ្ងាយ។

❖ ខ្សែឆ្នូតចំហៀង និងស្បែក

ជាស៊េរីបំពង់ដែលមានសរីរាង្គវិញ្ញាណនៅក្នុងស្បែកតាមបណ្តោយសងខាងខ្លួនត្រី។ លំញ័រចូលទៅក្នុងបំពង់តាមរន្ធលើស្បែក) pore) និងភ្ជាចសរីរាង្គវិញ្ញាណ ដែលបញ្ជូនចរន្តប្រសាទទៅខួរក្បាល ។ ខ្សែឆ្នូតចំហៀងត្រីជួយឱ្យត្រីដឹងអំពី ចរន្តទឹក សីតុណ្ហភាពទឹក និងរលកសូរសំឡេង។

ត្រីភាគច្រើនមានស្បែកគ្រើមគួរសម ដែលមានកោសិកាពិសេសបង្កើតរំអិល )Slimy mucus)។ កោសិកាពិសេសផ្សេងទៀតហៅថា Chromatophores ឬកោសិកាជាតិពណ៌) Pigment cells) ផ្តល់ឱ្យ ត្រីនូវពណ៌ជាច្រើន។ ក្រៅពី Chromatophores ត្រីជាច្រើនមានជាតិពណ៌ស ឬពណ៌ប្រាក់នៅក្នុងស្បែក និងស្រការបស់វា។ ក្រោមពន្លឺព្រះអាទិត្យ ជាតិពណ៌ទាំងនោះបង្កើតពណ៌ផ្លេកៗដូចពណ៌ឥន្ទធនូ ត្រីភាគច្រើនអាចប្រែពណ៌របស់វាឱ្យត្រូវនឹងមជ្ឈដ្ឋានជុំវិញ។ រំញោចនៃសរសៃប្រសាទត្រីភ្ជាចជាតិពណ៌នៅ ក្នុង Chromatophores ធ្វើឱ្យពណ៌របស់វាខ្មៅឬសជាងមុន។ ការធ្វើឱ្យខ្មៅឬធ្វើឱ្យសរបស់ Chromatophores បង្កើតបានជាពណ៌ខុសៗគ្នា ។

❖ ពុកមាត់

ឃើញមានចំពោះប្រភេទត្រីដែលរស់នៅផ្នែកបាត វាជួយដល់មុខងារភ្នែកនិងស្វែងរកចំណី។

តាមកំណត់ត្រាប្រទេសកម្ពុជាមានប្រភេទត្រីប្រមាណ ៥០០ប្រភេទ ក្នុងនោះមាន ៤៧៨ប្រភេទជាប្រភេទត្រីទឹកសាប។

តាម បានបញ្ជាក់ថាមាន ៥០០ប្រភេទត្រីទឹកសាបក្នុងនោះ៖

- ១៨ ប្រភទ ជាប្រភេទស៊ីសាច់កម្រិត សេ
- ១១១ ប្រភេទ ជាប្រភេទស៊ីសាច់កម្រិត បេ
- ២៤០ ប្រភេទ ជាប្រភេទស៊ីចម្រុះ ។

### គ.ប្រព័ន្ធសាច់ដុំ

ការបង្កើតជីវឧស្ម័ននៅក្នុងកោសិកាថនិកសត្វ អាចបង្កើនការបញ្ចេញ PGC-1α ហើយក្នុងការធ្វើអន្តរកម្មជាមួយ DNA អាចជួយរក្សាភាពល្អនៃហ្សែន។ មិនថាមុខងារ តាមរបៀបដូចគ្នានៅក្នុងត្រីដែរឬទេ។ ក្នុងផ្នែកខាងក្រោមយន្តការនៃភាពសាច់ដុំដែលត្រូវបានអង្កេតនៅក្នុងត្រីនឹងត្រូវពិនិត្យឡើងវិញ។ គួរឱ្យចាប់អារម្មណ៍នៃកត្តាដែលបានពិនិត្យរហូតមកដល់ពេលនេះមានតែ NRF-1 ប៉ុណ្ណោះដែលបានបង្ហាញពីការជាប់ទាក់ទងយ៉ាងច្បាស់ជាមួយនឹងការបញ្ចេញហ្សែនដែលបានអ៊ិនកូដប្រូតេអ៊ីន មីតូខនឌៀរ នៅក្នុងសាច់ដុំត្រី ។

ទម្រង់សាច់ដុំគឺជាលទ្ធផលនៃអន្តរកម្មរវាងហ្សែនប្រភេទសត្វនិងបរិស្ថាន។ ប្រភេទហ្សែនតែមួយអាចបណ្តាលឱ្យមានផូណូទីបជាច្រើនអាស្រ័យលើឥទ្ធិពលបរិស្ថាននៅក្នុងអ្វីត្រូវបានគេស្គាល់ថាជាប្លាស្ទិកហ្វីណូទីបិច។ នៅក្នុងត្រីពេញវ័យហ្វីណូទីបប្លាស្ទិកកើតឡើងតាមរដូវ ឬតាមចលនានៅជុំវិញចង្កោមបរិស្ថានហើយការផ្លាស់ប្តូរទាំងនេះគឺគិតថាអាចបញ្ច្រាសបាន។ ផ្ទុយទៅវិញឥទ្ធិពលបរិស្ថានកំឡុងពេល ontogeny អាចនាំឱ្យមានភាពខុសគ្នានិងទម្រង់សាច់ដុំដែលមិនអាចបញ្ច្រាស់បានដែលជាការបង្ហាញពីដំណើរអភិវឌ្ឍន៍ផ្សេងៗគ្នា។ សារៈសំខាន់នៃបទពិសោធន៍ជីវិតដំបូងនៅលើទម្រង់សាច់ដុំដែលត្រូវបានបង្ហាញនៅពេលក្រោយក្នុងជីវិតត្រូវបានគេទទួលស្គាល់ជាយូរមកហើយប៉ុន្តែទើបតែមានឥទ្ធិពលនៃការវិវត្តនៃការអភិវឌ្ឍន៍លើប្លាស្ទិចសាច់ដុំ និងការហែលទឹកចំពោះត្រីត្រូវបានបង្ហាញយ៉ាងច្បាស់។ សាច់ដុំគ្រោងឆ្អឹងដើរតួនាទីដ៏សំខាន់ជាច្រើននៅក្នុងត្រី រាប់ចាប់ពីការធ្វើចលនាដល់ការធ្វើការរំលាយអាហារក្នុងរាងកាយទាំងមូល។ ដោយសារសាច់ដុំបង្កើតបានជាសមាមាត្រសំខាន់នៃម៉ាស់រាងកាយត្រី សមត្ថភាពក្នុងការសម្របសម្រួលលក្ខណៈមេកានិច និងមេតាប៉ូលីសនៃជាលិកានេះជាមួយនឹងបរិស្ថានអុបទិក គឺជាលក្ខណៈសំខាន់ដែលអនុញ្ញាតឱ្យប្រភេទសត្វអាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌបរិស្ថាន។ ដូច្នេះ ប្លាស្ទិចហ្វីណូទីបនៃសាច់ដុំ គឺជាយន្តការសំខាន់មួយដែលធានាថាភារកិច្ចពាក់ព័ន្ធនឹងបរិស្ថានវិទ្យានៅតែអាចត្រូវបានអនុវត្តចំពោះមុខបរិស្ថានមេកានិច និងភាពតានតឹងថាមពល។

ត្រីជាញឹកញាប់ត្រូវប្រឈមមុខនឹងភាពតានតឹងក្នុងការចិញ្ចឹមសត្វដែលពួកគេមិនអាចចៀសផុត។ ខាងក្នុងការប្រែប្រួលជាក់លាក់នៅក្នុងទំហំនៃការឆ្លើយតបទៅនឹងភាពតានតឹង ដែលបានផ្តល់អាចឆ្លុះបញ្ចាំងពីភាពខុសគ្នានៅក្នុងការចាប់ផ្តើមនៃ"ហ្សែនសាច់ដុំ" និង កម្រិតនៃបទបញ្ជាមិនទាក់ទងគ្នា នៃទម្រង់សាច់ដុំ។ ពេលដែលត្រូវបានប៉ះពាល់នឹងសីតុណ្ហភាពខ្ពស់ ពួកវាអាចរស់នៅក្នុងបរិយាកាសនៅក្នុងដែលសីតុណ្ហភាពប្រែប្រួលតិចតួច។ ឧទាហរណ៏ eurythermal (Fundulus heteroclitus) គឺជាឧទាហរណ៍មួយនៃប្រភេទសត្វមួយ ដែលមានយុទ្ធសាស្ត្រទូទៅដែលឆ្លងកាត់សាច់ដុំប្លាស្ទិចយ៉ាង

សំខាន់ជាមួយនឹងការផ្លាស់ប្តូរសីតុណ្ហភាព ឆ្លុះបញ្ចាំងពីលក្ខណៈ" ល្អ" នៃបរិស្ថានកំដៅរបស់ពួកគេ។ ដូច្នេះភាពប្រែប្រួលនៃស្រ្តេស abiotic នៅក្នុងបរិយាកាសធម្មជាតិរបស់ប្រភេទសត្វអាចកំណត់ដែនកំណត់នៃប្លាស្ទិច phenotypic សាច់ដុំរបស់ពួកគេក្នុងការឆ្លើយតបទៅនឹងអថេរនោះ។




រូបទី ១.៤ ទម្រង់សាច់ដុំអាចផ្លាស់ប្តូរនៅក្នុងជីវិតដំបូងតាមរយៈការបង្ហាញពីការវិវត្តផ្សេងៗគ្នាគន្លងក្នុងដំណើរការអភិវឌ្ឍន៍ប្លាស្ទិច។ ប្លាស្ទិចដែលមិនអាចផ្លាស់ប្តូរបានអាចប៉ះពាល់នៅលើប្លាស្ទិច phenotypic ដែលអាចផ្លាស់ប្តូរបានដូចត្រីពេញវ័យ។ ភាពតានតឹងផ្នែកបរិស្ថានធ្វើសកម្មភាពលើការប្រែប្រួលហ្សែនរបស់ប្រជាករដើម្បីជះឥទ្ធិពលដល់កម្រិតខុសគ្នានៃប្លាស្ទិចសាច់ដុំនៅគ្រប់ដំណាក់កាល។

មុខងារសាច់ដុំប៉ះពាល់ដល់ដំណើរការដឹកនាំ ដែលក្នុងករណីជាច្រើនអាចមានផលប៉ះពាល់យ៉ាងខ្លាំងលើតួនាទីសារពាង្គកាយទាំងមូល និងនៅទីបំផុតមានភាពរឹងមាំនៅក្នុងការផ្លាស់ប្តូរ។ ដូច្នេះត្រូវបានគេប្រើជាប្រចាំដើម្បីជាវង្វាស់លទ្ធផលនៃសាច់ដុំប្លាស្ទិចភាពតានតឹង ផ្នែកបរិស្ថានឬថាមពលយូរអង្វែង។ ដោយសារអថេរបរិស្ថានជាច្រើនអាចប៉ះពាល់ដល់លក្ខណៈមេតាប៉ូលីស និងលក្ខណៈរូបនៃសាច់ដុំ ដែលទទួលខុសត្រូវចំពោះការបញ្ចេញថាមពល និងចលនាក្បាលម៉ាស៊ីនប្រកបដោយនិរន្តរភាព វាមានសារៈសំខាន់ណាស់ដែលត្រីឆ្លើយតបឱ្យបានត្រឹមត្រូវចំពោះភាពតានតឹង។ ថ្វីបើប្លាស្ទិចសាច់ដុំអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការរស់រានរបស់ត្រីក៏ដោយការយល់ដឹងអំពីមូលដ្ឋានគ្រឹះនៃយន្តការដែលពាក់ព័ន្ធនឹងការជួសជុលជាលិកានេះឡើងវិញ គឺមានកំណត់ខ្លះ។

លក្ខណៈរចនាសម្ព័ន្ធ និងមុខងារនៃសាច់ដុំត្រីផ្តល់នូវមធ្យោបាយសម្រាប់សកម្មភាពសមស្របលំនាំ។ ប្រភេទសរសៃសាច់ដុំផ្សេងៗគ្នានៅក្នុងត្រីត្រូវបានកំណត់ថាមានល្បឿនលឿន មធ្យម និងរមួលយឺត។ សរសៃត្រូវបានរៀបចំដោយមានរាងដូចប្លុករាងសំប៉ែតរាប់រយដែលហៅថា មីយ៉ូតូម ដែលត្រូវបានបំបែកដោយសន្លឹកនៃជាលិកាភ្ជាប់ដែលមានឈ្មោះថាមីយ៉ូសតា។ myotomes រត់ចុះតាមដងខ្លួននៃរាងកាយហើយត្រូវបានភ្ជាប់ទៅនឹងតំបន់ក្រោយដោយសរសៃពួរ។ នៅក្នុងត្រីភាគច្រើនក្រហម

(យឺត) សាច់ដុំមានទីតាំងស្ថិតនៅខាងក្រៅនិងស្របទៅនឹងអ័ក្សវែងនៃរាងកាយ។ វាត្រូវបានផ្សំឡើងដោយប្រភេទសរសៃយឺត I និងទ្រទ្រង់ការធ្វើចលនាដោយគ្មានអ័ក្ស។




| Fiber Type | Dominant MyATPase | Mitochondrial Density | Anaerobic Capacity |
|---|---|---|---|
| Slow | Type I | High | Low |
| Intermediate | Type IIa | Intermediate | Intermediate |
| Fast | Type IIb | Low | High |

(e)

រូបទី ១.៥ ប្រភេទសរសៃសំខាន់បីនៅក្នុងសាច់ដុំតាមអ័ក្សរបស់ត្រី គឺមានទំហំបានបែងចែកជាតំបន់ផ្សេងៗគ្នា។ សរសៃអុកស៊ីតកម្មយឺតៗ ស្ថិតនៅផ្នែកខាងក្រៅនៃសាច់ដុំនិងនៅក្នុងត្រីពេញវ័យពួកវាមានច្រើនបំផុតនៅជិត septum ផ្តេក។ សរសៃអុកស៊ីតកម្មមធ្យម (មធ្យម) លឿន I គឺដែលមានទីតាំងនៅជាប់នឹងសរសៃយឺតនិងសរសៃ glycolytic លឿន (F) បង្កើតបានជាសរសៃសាច់ដុំអ័ក្សដែលនៅសេសសល់។ (a – c) ផ្នែកតំណាងពី zebrafish ពេញវ័យ; (ក) សរសៃយឺតត្រូវបានកំណត់អត្តសញ្ញាណដោយប្រើប្រព័ន្ធភាពស៊ាំ គឺមី ជាមួយអង្គបដិប្រាណអេស ៥៨ (របារខ្នាតគឺ ៥០ μm)។ (ខ) សរសៃមធ្យមត្រូវបានកំណត់ដោយផ្អែកលើសកម្មភាពរបស់សកម្មភាព myosin-ATPase ដែលធន់នឹងអាល់កាឡាំង (គ) សរសៃយឺតនិងមធ្យមមានផ្ទុក myosin-ATPase ឆ្លុះបញ្ចាំងដោយសកម្មភាពនៃសកម្មភាព dehydrogenase succinate ។ (ឃ) ដ្យាក្រាមនៃផ្នែកឆ្លងកាត់ឆ្លងកាត់ត្រីពេញវ័យ (ខាងឆ្វេង) និងអំប្រីយ៉ុងក្នុងកំឡុងពេលបែងចែកចុង (ខាងស្តាំ) បង្ហាញពីការរៀបចំប្រភេទសរសៃ (អេប្រអប់ពណ៌ខៀវបង្ហាញពីតំបន់សាច់ដុំដែលបង្ហាញក្នុងអក្សរ) គ) ។ ផ្នែកស៊េរីនៃ

សរសៃសាច់ដុំដូចគ្នាត្រូវបានតំណាងជាមួយអក្សរ (s, i, f) នៅក្នុង a – c ។ (ង) សង្ខេបពីភាពខុសប្លែកគ្នានៃ phenotypic សំខាន់ៗ។

សាច់ដុំសត្រូវបានកំណត់សម្រាប់អត្រាលំហូរខ្ពស់តាមរយៈគ្លីកូលីស្សូស។ សរសៃនៃម៉ាសសាច់ដុំនេះ គឺធំជាងសាច់ដុំក្រហមនិងផ្តល់ថាមពលខ្ពស់។ សរសៃសាច់ដុំក្រហមមានទំហំតូចជាងហើយជំពាក់ឈ្មោះរបស់ពួកគេចំពោះកម្រិតខ្ពស់នៃអេម៉ូក្លូប៊ីនដែលពួកគេមានដើម្បីជួយសម្រួលដល់ខួរក្បាល។ ការផ្គត់ផ្គង់ អុកស៊ីសែន ពួកគេមានឌីអិនអេ ធំជាងដង់ស៊ីតេ myosin-ATPase កាន់តែធំ កន្លែងផ្ទុកជាតិខ្លាញ់កើនឡើងនិងសមត្ថភាពខ្ពស់សម្រាប់អុកស៊ីតកម្មអាស៊ីតខ្លាញ់ បើប្រៀបធៀបទៅនឹងសាច់ដុំស ។ នៅក្នុងប្រភេទត្រីភាគច្រើនរហូតដល់ទៅ ៨៥% នៃសាច់ដុំដើមនិង៦០% នៃទម្ងន់រាងកាយមានសាច់ដុំពណ៌ស។ សមាមាត្រនៃពណ៌ក្រហមសាច់ដុំមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងប្រភេទសត្វ ហើយប្រភេទខ្លះមានប្រភេទសាច់ដុំទីបីដែលមានពណ៌ផ្កាឈូកជាមួយនឹងការចុះខ្សោយកម្រិតមធ្យម (ប្រភេទ IIa myosin-ATPase) និងលក្ខណៈមេតាប៉ូលីស ។

ភាពខុសគ្នានៃប្លាស្ទិចនៅក្នុងប្រភេទសាច់ដុំទាំងបីនេះកើតឡើងដោយសារតែនីមួយៗរកឃើញនិងឆ្លើយតបភាពតានតឹងនៅក្នុងវិធីផ្សេងគ្នា។ លើសពីនេះទៅទៀតនៅក្នុងប្រភេទសាច់ដុំតែមួយការឆ្លើយតបទៅនឹងភាពតានតឹងពិសេសមួយអាចពាក់ព័ន្ធនឹងការកើនឡើងទំហំជាតិសរសៃ (ឧទាហរណ៍ជំងឺលើសឈាម) ខណៈសាច់ដុំដូចគ្នាអាចឆ្លើយតបទៅនឹងមួយទៀតភាពតានតឹងជាមួយនឹងការផ្លាស់ប្តូរទម្រង់មេតាប៉ូលីសរបស់វាប៉ុន្តែគ្មានការលូតលាស់លើសឈាម។ ការបែងចែកប្រភេទសរសៃសាច់ដុំបានជួយសម្រួលដល់លក្ខណៈនៃការជ្រើសរើសលំនាំជាមួយនឹងការផ្លាស់ប្តូរអាំងតង់ស៊ីតេ ក្នុងការហែលទឹក ហើយនៅពេលល្បឿនហែលទឹកកើនឡើង ដំបូងភាពយឺតសរសៃសាច់ដុំ បន្ទាប់មកមានកម្រិតមធ្យមហើយចុងក្រោយសរសៃសាច់ដុំលឿននៅអាំងតង់ស៊ីតេខ្ពស់។ ល្បឿនហែលទឹកកម្រិតទាបបំផុតសម្រាប់ការជ្រើសរើសសរសៃផ្សេងៗប្រភេទខុសគ្នាយ៉ាងខ្លាំងរវាងប្រភេទ និងលក្ខខណ្ឌបរិស្ថាន។ សាច់ដុំពណ៌សអាចត្រូវបានជ្រើសរើសក្នុងអំឡុងពេលហែលទឹកប្រកបដោយនិរន្តរភាពនៅក្នុងប្រភេទសត្វមួយចំនួន ប៉ុន្តែត្រូវបានកំណត់ចំពោះការផ្ទុះដែលមិនមាននិរន្តរភាពហែលទឹកនៅក្នុងអ្នកដទៃហើយភាពខុសគ្នាទាំងនេះអាចឆ្លុះបញ្ចាំងពីការប្រែប្រួលជាក់លាក់នៃអេរ៉ូប៊ិកសមត្ថភាព និងលំនាំខាងក្នុងនៃប្រភេទសាច់ដុំនេះ។ វាឈរលើហេតុផលនោះ បម្រែបម្រួលនៃការឆ្លើយតបនៃសាច់ដុំពណ៌សទៅនឹងការបណ្តុះបណ្តាលលំហាត់ ដែលបានឃើញនៅក្នុងការសិក្សាផ្សេងៗគ្នា គឺដោយសារតែជម្រើសនៃល្បឿនបណ្តុះបណ្តាលភាពខុសគ្នានៃសាច់ដុំលំនាំនៃការជ្រើសរើសឬលក្ខណៈនៃសាច់ដុំពណ៌សរបស់ប្រភេទសត្វ។

❖ **មុខងាររបស់Hb:** ករណីសម្ពាធអុកស៊ីសែនដូចគ្នានោះ កម្រិតអុកស៊ីសែនក្នុងប្លាស្មា មានតិចជាងក្នុងឈាម។ អុកស៊ីសែននៅ Erythrocyte រួមផ្សំជាមួយ Hb→Hbអុកស៊ីសែន ។ 1 gr Hb អាចចាប់យក អុកស៊ីសែន = 1,34 $cm^3$ ប៉ុន្តែពពួក agnatha (monomeric) ដឹកនាំអុកស៊ីសែនបានតិច។ Hb ចាប់យក អុកស៊ីសែន→Hbអុកស៊ីសែនមិនចាំចូលរួមនៃអំពើរបស់ អង់ស៊ីម ដោយគ្រាន់តែត្រូវការសម្ពាធ អុកស៊ីសែន(Pអុកស៊ីសែន) នៅស្រកី ក្នុងករណី Pអុកស៊ីសែន កើននោះ Hb+អុកស៊ីសែន →Hbអុកស៊ីសែន នៅជាលិកា Pអុកស៊ីសែន ទាបនោះ Hbអុកស៊ីសែន→Hb+អុកស៊ីសែន បានយ៉ាងងាយ។

– $^{O}$C (Oxygen capacity)គឺជាកម្រិតអុកស៊ីសែនដែលដឹកនាំដោយឈាម ឬកោសិកាឈាម ដោយគិតខ្នាតជា Volume/100ml or Mole/l កម្រិត $^{O}$Cនេះអាស្រ័យទៅតាម៖

– ត្រី ឬសត្វឆ្អឹងកងខ្នងមានសីតុណ្ហភាពកក្នុងសរីរាង្គប្រែប្រួល < ពពួក ថនិកសត្វ និងពពួកសត្វស្លាបពី៥→២

– ត្រីមានសរីរាង្គដកដង្ហើមរង < ត្រីរស់នៅផ្នែកស្រទាប់លើ(មធ្យម 19,9 vol)> ត្រីនៅបាត(3,4-8,4vol%)

– ពពួកសត្វនៅតូច <ពពួកសត្វពេញវ័យ

– ត្រីដែលមានចលនាសកម្ម ដូចត្រីកាធូ >ត្រីចលនាយឺតដូចត្រី Toad fish

❖**លំនឹងខ្សែងកោងអុកស៊ីសែន៖** ឈាមរបស់សត្វក្នុងទឹកមានសម្ពាធ អុកស៊ីសែន>សត្វថនិកសត្វ កូន

ត្រីឈាមត្រូវការមាន Pអុកស៊ីសែន>ត្រីពេញវ័យ។ ដើម្បីប្រៀបធៀប Pអុកស៊ីសែន នៃការដកដង្ហើម យើងប្រើ Pអុកស៊ីសែន=50, Pអុកស៊ីសែន=95 ដែល Hb បង្កើតHbអុកស៊ីសែន។ តាមនេះករណី: P អុកស៊ីសែន=0 នោះគ្មាន Hbអុកស៊ីសែនពេល Pអុកស៊ីសែន កើននោះ Hbអុកស៊ីសែន កើន។

$$Y=\frac{100\left(\frac{P}{P50}\right)n}{1+\left(\frac{P}{P50}\right)n} \text{ or } Y=\frac{100Hb_{\text{អុកស៊ីសែន}}}{Hb+Hb_{\text{អុកស៊ីសែន}}}$$

Y=ជាភាគរយដែល Hbចាប់យក អុកស៊ីសែន

P=សម្ពាធរបស់ អុកស៊ីសែន $mm^3$/Hg( n>1អំពើរបស់ Heme និងកើនសម្ពាធ អុកស៊ីសែន )

❖កត្តាមានឥទ្ធិពលដល់ខ្សែកោងលំនឹង អុកស៊ីសែន ( លំនឹងHb )

**អុកស៊ីសែន:** ករណី កាបូនឌីអុកស៊ីត កើនឡើងនោះឱ្យខ្សែងកោងងាកទៅស្តាំធ្វើឱ្យលទ្ធភាពឆ្អែតរបស់ Hb ត្រូវថយចុះ។ ឧ: ត្រីមានសម្ពាធ អុកស៊ីសែន ខ្ពស់ អុកស៊ីសែន និងទាប។

Y ត្រីមានសម្ពាធ អុកស៊ីសែន ខ្ពស់ ( ត្រី Salmon )

X ត្រីមានសម្ពាធ អុកស៊ីសែន ទាប( កាបសាមញ្ញ )

ផ្អែកលើលក្ខណៈក្រាភិចនេះ៖ ត្រី Salmon ត្រូវការ អុកស៊ីសែន ច្រើន ( Pអុកស៊ីសែនខ្ពស់ )

ត្រីកាបសាមញ្ញត្រូវការ អុកស៊ីសែន តិច ( Pអុកស៊ីសែនទាប )

តាមលក្ខណៈទាំងពីរ Δy>Δx

បើ ( Pអុកស៊ីសែន=50 )ជាលទ្ធផល៖

- Pកាបូនឌីអុកស៊ីត កើននោះ Hbអុកស៊ីសែន↓
- Pកាបូនឌីអុកស៊ីត ↓នោះ Hbអុកស៊ីសែន ↑
- **pH:** ប្រហាក់ប្រហែលឥទ្ធិពល កាបូនឌីអុកស៊ីត ជារួម pH ↑ធ្វើឱ្យខ្សែកោងងាកឆ្វេង និងផ្ទុយទៅវិញ pH ↓នោះខ្សែ

កោងងាកស្តាំ។ជារួម៖

- pH ↑នោះ Hbអុកស៊ីសែន ↑
- pH ↓នោះ Hbអុកស៊ីសែន ថយចុះ។
- $t^0$C( សីតុណ្ហភាព )៖ ត្រីជាសត្វប្រែប្រួល $t^0$C ដូចនេះឈាមវាមានលក្ខណៈប្រែប្រួលទៅតាម $t^0$Cដែរ។ ពេលសីតុណ្ហភាពកើននោះធ្វើឱ្យខ្សែកោងងាកទៅស្តាំ និងផ្ទុយវិញ ( Pអុកស៊ីសែន )ជារួម៖

\+ ពេលសីតុណ្ហភាពកើននោះ Hbអុកស៊ីសែនថយចុះ

\+ ពេលសីតុណ្ហភាពថយចុះនោះ Hbអុកស៊ីសែនកើនឡើង

### ខ/ ការដឹកនាំកាបូនឌីអុកស៊ីត

❖ **Mechanism ដឹកនាំកាបូនឌីអុកស៊ីត:** ក្នុងឈាមត្រីមាន កាបូនឌីអុកស៊ីត តែ 2,7%។

កាបូនឌីអុកស៊ីត ក្នុងឈាមត្រីមានទម្រង់រួមផ្សំជា៖ ទម្រង់អំបិល Bicabonat មាន 80% and 20% ជា Hbកាបូនឌីអុកស៊ីត( Carbamyl )។ ក្នុងនេះយើងសិក្សាស្រាវជ្រាវតែក្នុងទម្រង់ Bicabonat។

- **ការរួមផ្សំនិងបំបែកនៃអំបិល Bicabonat**

កាបូនឌីអុកស៊ីតរលាយពីជាលិកា(Tissue) ចូលក្នុងឈាមតាម កម្រិតលម្អៀងពីសម្ពាធ ហើយនាំចូលទៅប្លាស្មា។

កាបូនឌីអុកស៊ីតមួយផ្នែកតូចរួមផ្សំជាមួយ $H_2O \rightarrow H_2CO_3$ (កាបូនឌីអុកស៊ីត$+H_2O \rightarrow H_2CO_3$ កកើតនៅប្លាស្មា)

នៅ Erythrocyte កាបូនឌីអុកស៊ីត$+H_2O \rightarrow H_2CO_3$ក្រោមអំពើ Carbonic Anydrate(CA), $H_2CO_3$បម្លែងយ៉ាងរហ័ស $H_2CO_3 \leftrightarrow H^+ + HCO_3^-$។ ឈាមមួយផ្នែកចាប់យក កាបូនឌីអុកស៊ីតពីជាលិកា ដើម្បីបង្កើនH2CO3 មួយផ្នែកទៀតដោយ Pអុកស៊ីសែនថយចុះ ហើយ Pកាបូនឌីអុកស៊ីត ↑ដូចនេះ អ៊ីយ៉ុង $H^+$, $HCO_3^-$ កើនឡើង ធ្វើឱ្យ pHថយចុះអាស្រ័យហេតុនេះ Hbអុកស៊ីសែន ងាយបំបែកផ្តាច់ដោយផ្តល់ អុកស៊ីសែន ឱ្យជាលិកាប្រើប្រាស់៖ K Hbអុកស៊ីសែន→K Hb+អុកស៊ីសែន↑ (ដោយ Hb អុកស៊ីសែន មានទម្រង់ជាអាស៊ីត ដូចនេះត្រូវរួមផ្សំ $K^+$បង្កើត KHbអុកស៊ីសែន) KHb ជាអាស៊ីតខ្សោយជា $H_2CO_3$ ត្រូវបំបែក រួចរួមផ្សំ $K^+$ ឱ្យជាអំបិល K $HCO_3$: $KHb \rightarrow K^+ + Hb$. $K^+ + HCO_3 \rightarrow KHCO_3$(នៅErythrocyte) $Hb^- + H^+ \rightarrow H\ Hb$(នៅ Erythrocyte)ដោយ កាបូនឌីអុកស៊ីត កើនទៅក្នុងឈាមនោះ $HCO_3$ កើនអតិប្បរមាក្នុងប្លាស្មា។ ដូចនេះ $HCO_3^-$ ឆ្លងកាត់ ភ្នាស Erythrocytet to Plasma រួមផ្សំ Na+ បង្កើតជា NaHCO3ព្រមជាមួយនោះ $Cl^-$ រួមផ្សំជាមួយ $H^+$ បង្កើត HCl

$HCO_3^- + Na^+ \rightarrow Na\ HCl$(នៅក្នុង Plasma)

$Cl^- + H^+ \rightarrow HCl$(នៅក្នុង Erythrocyte)

ដូច្នេះ កាបូនឌីអុកស៊ីត សុទ្ធតែប្រែក្លាយជា K $HCO_3$និង $NaHCO_3$ជាអំបិល Bicabonat

នៅស្រកី៖ Pកាបូនឌីអុកស៊ីត↓នោះ $H_2CO_3$បម្លែង $H_2CO_3 \rightarrow H_2O$+កាបូនឌីអុកស៊ីត↑ពេលនោះ HHb រួមផ្សំ អុកស៊ីសែនឱ្យ HHbអុកស៊ីសែន(Acide oxyhemoglobine)

HHb+អុកស៊ីសែន→HHbអុកស៊ីសែន(នៅក្នុង Erythrocyte)

HHb ជាអាស៊ីតខ្លាំងជាង $H_2CO_3$ នោះវាចាប់យក $K^+$ របស់ $KHCO_3$ដើម្បីបង្កើតប៉ូតាស្យូម oxyhemoglobine និងរំដោះ $HCO_3^-$ រួច $HCO_3^-$ វារួមផ្សំ $H^+ \rightarrow$H2CO3ហើយវាបានបម្លែងបំបែក:

$KHCO_3 \rightarrow K+ + HCO_3^-$(នៅ Erythrocyte)

Hbអុកស៊ីសែន$^-$+K+→KHbអុកស៊ីសែន(នៅ Erythrocyte)

$HCO_3^- + H^+ \rightarrow H2CO_3 \rightarrow H_2O$+កាបូនឌីអុកស៊ីត↑(នៅ Erythrocyte)

ដាហេតុឱ្យ $HCO_3$- ក្នុង Erythrocyte ថយចុះធ្វើឱ្យ $HCO_3^-$ ពីប្លាស្មាជ្រាបចូល Erythrocyte និងផ្ទុយមកវិញ $Cl^-$ ពី Erythrocyte ទៅ plasma (មានលក្ខណៈផ្ទុយគ្នាទៅជាលិកា)

ក្នុងពេលនោះ $NaHCO_3$ ក្នុងផ្លាស្មាបានផ្ដាច់ $Na^+$ and $HCO_3^-$: $NaHCO_3 \rightarrow Na^+ + HCO_3^-$ $HCO_3^-$ចូលទៅក្នុង Erythrocyte ដើម្បីរួមផ្សំ $H^+$ បង្កើត$H_2CO_3$:

$NaHCO_3 \rightarrow Na^+ + HCO_3^-$ (Plasma)

$HCl \rightarrow H^+ + Cl^-$ (Erythrocyte)

$H^+ + HCO_3^- \rightarrow H_2CO_3 \rightarrow H_2O +$ កាបូនឌីអុកស៊ីត↑ (ក្នុង Erythrocyte)

$Na^+ + Cl^- \rightarrow NaCl$ (ក្នុង Plasma)

- **ការរួមផ្សំ និងដឹកនាំ កាបូនឌីអុកស៊ីត ដោយផ្ទាល់**

**កាបូនឌីអុកស៊ីត** ឆ្លងចូលទៅ Erythrocyte មួយផ្នែកតិចរួមផ្សមដោយផ្ទាល់ជាមួយ $NH_2$ នៃ ម៉ូលេគុលHb ដើម្បីបង្កើត Carbamin (ប្រមាណ ២០ភាគរយនៃ ឧស្ម័នកាបូនិច)

$Hb\text{-}NH_2 +$ កាបូនឌីអុកស៊ីត $\leftrightarrow HbNH\text{-}COOH$ (Carbamin)

Carbamin ចងសម្ព័នមិនរឹងមាំទេ ងាយរងប្រតិកម្ម ដើម្បីរំដោះចេញនូវ កាបូនឌីអុកស៊ីត ប្រតិកម្មនៅជាលិកាក្នុងករណី Pកាបូនឌីអុកស៊ីត ខ្ពស់ ដើម្បីចាប់យក កាបូនឌីអុកស៊ីត។ ប្រតិកម្មនៅស្រកីដើម្បីផ្ដាច់ចេញ កាបូនឌីអុកស៊ីត ក្នុងករណី Pកាបូនឌីអុកស៊ីត តិច។

ឆ្លងតាមប្រតិកម្មជាច្រើន ដូចខាងលើដែលនាំឱ្យ **Hb**ដឹកនាំ **អុកស៊ីសែន**ពីស្រកីទៅគ្រប់ផ្នែកនៃជាលិកា និងនាំយក កាបូនឌីអុកស៊ីត ពីចាលិកាត្រឡប់មកផ្នែកស្រកីវិញដើម្បីបញ្ចេញមកក្រៅ។

**-អង់ស៊ីម Carbonic Anydrate(CA):** កាបូនឌីអុកស៊ីត រលាយក្នុហាឈាម និង ទឹកខ្លាំងជាងអុកស៊ីសែន ២៥ដង។

នៅជាលិកាឈាមរួមផ្សំជាមួយ កាបូនឌីអុកស៊ីត ចំណែកនៅស្រកីរំដោះ កាបូនឌីអុកស៊ីត ។ ស្រកីជាសរីរាង្គបណ្ដូ អុកស៊ីសែន និងបញ្ចេញ កាបូនឌីអុកស៊ីត ខ្លាំងជាងនៅជាលិកា។

ឈាមអាចដឹកនាំ កាបូនឌីអុកស៊ីត យ៉ាងច្រើនដែលរលាយក្នុងឈាមជាទម្រង់ Bicabonat តាងដោយប្រតិកម្ម:

កាបូនឌីអុកស៊ីត$+ H_2O \leftrightarrow H+ + HCO_3^-$

នៅស្រកី Bicabonat ជួបជាមួយ អុកស៊ីសែន នោះប្រតិកម្មបង្កើតចេញ កាបូនឌីអុកស៊ីត and $H_2O$ ប៉ុន្តែសីតុណ្ហភាពនៃសារពាង្គកាយពន្លឿនប្រតិកម្មមិនមានប្រសិទ្ធភាពដើម្បីបណ្ដូខ្យល់ដកដង្ហើមឡើយ។

ដូចនេះត្រូវពឹងលើ Erythrocyte មាន អង់ស៊ីម ដែលមានអំពើលើប្រតិកម្មគីមីនេះជាសំខាន់ អង់ស៊ីម Carbonic Anhydrase ក្នុងករណី Erythrocyte ត្រូវបែកនោះមុខងារ CA គ្មានលទ្ធភាពសកម្មភាពដែរ។

**ខ្សែកោងលៅនឹង កាបូនឌីអុកស៊ីត:**

កម្រិតបរិមាណ កាបូនឌីអុកស៊ីតដូច អុកស៊ីសែន ។

វាវិសេតួមានទម្រង់ប្រព័ន្ធ Mattress មួយយ៉ាងខ្សោយនៃបណ្តា Cation ។ វាអាចផ្ទុកឧស្ម័នកាបូនឌីអុកស៊ីត តិចជាងពពួកសត្វរស់លើគោក ប៉ុន្តែ %កាបូនឌីអុកស៊ីត ដែលទទួលបាននូវជាលិកា និង បញ្ចេញនៅស្រកីច្រើនជាងសត្វលើគោក។ យើងឃើញ vol%កាបូនឌីអុកស៊ីត ក្នុងឈាមត្រី Makeral តិចជាងក្នុងឈាមត្រីពីព្រោះមជ្ឈដ្ឋានត្រី Makeral នៃទឹកសមុទ្រមានប្រព័ន្ធ Mattreess ចំណែកបរិស្ថាននៃត្រីគ្មានប្រព័ន្ធ Mattreess ទេ។

## ២.៣ ការផ្លាស់ប្តូរខ្យល់ ទឹក និងឈាមនៅស្រកី

ការផ្លាស់ប្តូររវាងឈាម និង ទឹកនៅស្រកីអាចបង្រួម ដោយអនុវត្តប្រើ៖

–R: សមាមាត្រផ្លាស់ប្តូរខ្យល់ពិត

R=Vw×Sw( Tw in – Tw out )

R=Vb×Sb( Tb out – Tb in )

កំណត់សម្គាល់

w= ទឹក b= ឈាម v=volume S=មេគុណរលាយនៃអុកស៊ីសែន T=សម្ពាធនៃខ្យល់ in= ចូល out= ចេញ

–Rmax សមាមាត្រផ្លស់ប្តូរខ្យល់អតិប្បរមាតាមទ្រឹស្តី៖

Rmax= Vb×Sb( Tw in –Tw in )

ពីនេះយើងទាញបានរូបមន្ត ជាភាគរយ

$$E\% = \frac{\mathrm{R}}{Rmax} \times 100$$

សមាមាត្រ $\frac{\mathrm{Sw{\times}Vw}}{Vb{\times}Sb} < 1$ការប្រើប្រាស់ អុកស៊ីសែន ទឹកទាបបំផុត

តាងផលធៀប $\frac{\mathrm{Sw{\times}Vw}}{\mathrm{Vb{\times}Sb}} = \frac{\mathrm{Cw}}{Cb}$ ប្រៀបជាមួយឈាមនោះ ឈាមងាយស្រូបយក អុកស៊ីសែន ជាង។

–សរីរាង្គដឹកនាំមានៈ ផ្ទៃនៃស្រកី ផ្ចិតនៃស្រកី កាំនៃស្រកី និងមាឌទឹកឆ្លងកាត់ស្រកី។

–ភាពសមស្របទិសនៃចរន្តរត់ពីរ៖ ស្របទិស និងបញ្ច្រាសទិស។

ដូចនេះ E អាស្រ័យដោយកត្តាបីខាងលើ និង ផលធៀប ដំណើរការប្តូរផ្លាស់ខ្យល់រវាង ឈាម និង ទឹក ជាដំណាក់កាលដំណើរការយ៉ាងស្មុគស្មាញ។

ការកើនឡើងនៃ E% អាស្រ័យដោយកត្តា៖

–បរិមាណ អុកស៊ីសែន នៅក្នុងទឹកមានតិចជាងច្រើនដងជាមួយ អុកស៊ីសែន នៅក្នុងឈាម

–ករណី $\frac{Cw}{Cb} \approx 0$ នោះមិនអាស្រ័យ ទៅតាមទិសចរន្តទឹកបញ្ច្រាស ឬស្របទិសគ្នានោះឡើយ។

–ករណី$\frac{Cw}{Cb} = 1$ភាពបញ្ច្រាសនៃចរន្តទឹក និងឈាមមានលក្ខណៈល្អប្រសើរ (លើស 80% និងតិចជាង50%)

–អាស្រ័យដោយមាឌនៃផ្ចិតស្រកី និងការជួបជិតស្និតរវាងឈាម និងទឹក។

## ២.៤ ការផ្លាស់ប្តូរខ្យល់រវាងឈាម និងចំណាត់តាំងជាលិកា

ការផ្លាស់ប្តូរនេះអាស្រ័យដោយកត្តា៖ pH, កម្រិត កាបូនឌីអុកស៊ីត និង អុកស៊ីសែន នៅជលិកា (pH មានលក្ខណៈអាស៊ីតខ្លាំង ធ្វើឱ្យថយចុះលទ្ធភាពចងសម្ព័ន្ធរវាង អុកស៊ីសែន និង Hb) ប្រការនេះមានអត្ថន័យយ៉ាងសំខាន់នៃសរីរសាស្ត្រដោយបង្កើតសកម្មភាពនៃសរីរាង្គនោះនៅជាលិកាបានប្រមូលផ្តុំបរិមាណ កាបូនឌីអុកស៊ីតយ៉ាងច្រើន នៅពេលឈាមមកដល់ឈាមបានផ្តាច់ អុកស៊ីសែន ចេញយ៉ាងច្រើន។

## ២.៥ Frequency ដកដង្ហើម

គឺជាចំនួនដងនៃដង្ហើមក្នុង ១ខ្នាតរយៈពេល(ដង/នាទី)។ Frequency ដកដង្ហើមកំណត់ដោយ Intensity ដកដង្ហើមត្រីជារួម:

+ កូនត្រីមាន Frequency ដកដង្ហើមច្រើនជាងត្រីពេញវ័យ
+ ត្រីរស់នៅស្រទាប់បាតមាន Frequency ដកដង្ហើសារចជាងត្រីរស់នៅស្រទាប់លើ ដោយត្រីស្រទាប់

បាតមានកាំស្រកីធំជាងត្រីស្រទាប់លើ វគ្គនៃចលនារបស់វាយឺតៗ ធ្វើឱ្យលំនឹងរវាងទឹក ឈាមកកើតយ៉ាងយឺត ព្រមទាំងស្រទាប់បាតខ្សត់ អុកស៊ីសែន ជាងស្រទាប់លើ។

## ២.៦ កម្រិតប្រើប្រាស់ អុកស៊ីសែន

ជាសមាមាត្រភាគរយរវាងកម្រិត អុកស៊ីសែន បានប្រើប្រាស់ពេលឆ្លងកាត់ស្រកី អុកស៊ីសែន និងកម្រិត ក្នុងទឹកពេលជួបស្រកី។ កម្រិតប្រើប្រាស់ អុកស៊ីសែន ប្រែប្រួលតាមមាឌទឹកមាន ថយចុះដោយមូលហេតុពីរ៖

+ មាឌទឹកឆ្លងកាត់ក្នាសស្រកីមានរយៈពេលយូរ

Ex: ទឹកចូលមាន អុកស៊ីសែន=4mg/l ឆ្លងកាត់ស្រកីមាន អុកស៊ីសែន=3mg/l នោះកម្រិតប្រើប្រាស់អុកស៊ីសែន=1/4=25% ។

+ ទឹកដែលមានកម្រិត អុកស៊ីសែន រលាយច្រើនក្នុងពេលឆ្លងកាត់មិនមែនសុទ្ធតែបានប៉ះផ្ទាល់ជាមួយនឹងភ្នាសស្រកី ដែលធ្វើឱ្យ អុកស៊ីសែន ជួបផ្ទាល់ឈាមមិនបានជិតស្និត ជាហេតុធ្វើឱ្យកម្រិតប្រើប្រាស់ អុកស៊ីសែន ថយចុះ។

## ៣. កត្តាមានឥទ្ធិពលដល់ការដកដង្ហើម

### ៣.១ សីតុណ្ហភាព

ពេលសីតុណ្ហភាពកើននោះ Metabolism នៃសារពាង្គកាយកើន។ ដូចនេះតម្រូវការ អុកស៊ីសែនកើន ប៉ុន្តែសីតុណ្ហភាពកើននោះបរិមាណ អុកស៊ីសែន រលាយក្នុងទឹកថយចុះ ធ្វើឱ្យលទ្ធភាពរួមផ្សំ អុកស៊ីសែន ជាមួយ ថយចុះ។ តម្រូវការ អុកស៊ីសែន កើនតែលទ្ធភាពឆ្អែត Hbអុកស៊ីសែន ថយចុះ ធ្វើឱ្យត្រីបង្កើនការដកដង្ហើម(ចលនាច្រើន) ដើម្បីបង្កើតចលនាឈាមទៅដល់ស្រកី ក្នុងករណីសីតុណ្ហភាពកើនដល់កម្រិតចំណុច Threshold នៃត្រីនោះ Frequency ដកដង្ហើមរបស់ត្រីថយអប្បរមា។

សរីរាង្គទទួលរំញោចសីតុណ្ហភាពនៃប្រភេទត្រីឆ្អឹងរឹង គឺប្រព័ន្ធវិញ្ញាណខ្សែឆ្នូតចំហៀង ចំពោះត្រីឆ្អឹងទន់សរីរាង្គ ទទួលរំញោចសីតុណ្ហភាពស្ថិតនៅផ្នែកមុខនៃក្បាល។

### ៣.២ អុកស៊ីសែន និង កាបូនឌីអុកស៊ីត

ចំពោះពពួកត្រីឆ្អឹងរឹង និង ដើម្បីទប់ទល់នឹងការសេសសល់ អុកស៊ីសែន និង កង្វះ អុកស៊ីសែន នោះវាបង្កើតមាឌទឹកឆ្លងកាត់ស្រកី។

Ex: ពិនិត្យត្រី Tench, P=60gr

1 ជា Frequency ដកដង្ហើម

2 ជា Amplitude បើកមាត់

3 ជា Amplitude បើកពង្រូបស្រកី

-ក្នុងករណី Pអុកស៊ីសែន ថយចុះ 55-70 mm/Hgគ្មានឥទ្ធិពលដល់ការដកដង្ហើម ប៉ុន្តែបើអុកស៊ីសែនបន្តការថយចុះទៀតនោះ Frequency ដកដង្ហើម និង Amplitude កើនជាលំដាប់ផងដែរ។

ក្នុងករណី កើនដល់ នោះត្រីបង្កើនជាសន្សឹមៗនៃ ប៉ុន្តែ Frequency មានការថយចុះ។

### ៣.៣ ការដកដង្ហើមពេលធ្វើចលនា

ពេលសរីរាង្គធ្វើចលនា នោះ Metabolism និង ដំណើរការអុកស៊ីតកម្មកើនឡើង បរិមាណ អុកស៊ីសែន ដែលសរីរាង្គត្រូវការកើនឡើង និងបរិមាណ កាបូនឌីអុកស៊ីត ដែលសរីរាង្គបញ្ចេញកើនដែរ ករណីនេះការដកដង្ហើមកើនយ៉ាងរហ័ស ដើម្បីបង្កើន មាឌទឹកឱ្យឆ្លងកាត់ស្រកី។

ចលនាបេះដូង និងឈាមរត់ម្តងៗកើនឡើង ធ្វើឱ្យល្បឿនឈាម និងបរិមាណឈាមដល់ស្រកីកើនឡើង។

ពេលសរីរាង្គមានចលនាខ្លាំងនោះ បរិមាណ កាបូនឌីអុកស៊ីត ប្រមូលផ្តុំនៅជាលិកាយ៉ាងច្រើន រួមជាមួយនោះអ៊ីយ៉ុង $H^+$ ក្នុងឈាមកើនឡើង ពេលឈាមរត់ចូលដល់ជាលិកា ដែលជាកន្លែងមានលក្ខណៈអាស៊ីត នោះឈាមបានបញ្ចេញ អុកស៊ីសែន នូវបរិមាណយ៉ាងច្រើន។

### ៣.៤ ឥទ្ធិពលជាតិពុលគីមី

បណ្តាលសារធាតុពុលគីមី កកើតក្នុងទឹកនូវបរិមាណជាច្រើនអាចបណ្តាលឱ្យពុលងាប់ត្រី និងសារធាតុអាស៊ីត ដែលបណ្តាលឱ្យជាលិកាស្រកីរបួស(បាត់លក្ខណៈធម្មតាក្នុងការបណ្តូរខ្យល់)ដោយបង្កើតភ្នាសក្រាស់រាំងស្តាត់ការជួបគ្នារវាងទឹក និងឈាម ធ្វើឱ្យត្រីស្លាប់ដោយខ្វះ អុកស៊ីសែន ក្រៅពីនេះសារធាតុពុល អាចធ្វើឱ្យរបួសផ្នែកក្រៅសរីរាង្គ រួចចូលទៅក្នុងបំពង់រំលាយអាហារ ធ្វើឱ្យប្រែប្រួលសកម្មភាពធម្មតានៃសរីរៈ និង ជាពិសេសធ្វើឱ្យសរីរាង្គដកដង្ហើមរង ដូចជាស្បែក ពោះវៀន បាត់បង់មុខងារ។

## ៤. ការដកដង្ហើមដោយប្រព័ន្ធដកដង្ហើមរង

សរីរាង្គដកដង្ហើមរបស់ត្រីសំខាន់ គឺស្រកី។ ដោយមជ្ឈដ្ឋានរស់នៅជានិច្ចជាកាលមានការប្រែប្រួលសមាសភាពខ្យល់ ជាពិសេស អុកស៊ីសែនដូចនេះប្រភេទត្រីមួយចំនួនដកដង្ហើមតាមស្រកីមិនគ្រាន់នូវបរិមាណ អុកស៊ីសែន សម្រាប់ប្រើប្រាស់ធ្វើឱ្យវាលូតលាស់នូវប្រព័ន្ធដកដង្ហើមរងរួមមាន៖ ពោះវៀន ស្បែក សរីរាង្គលើស្រកី និងសួត... ។ល។

ចំពោះកត្តាមជ្ឈដ្ឋានមិនមានឥទ្ធិពលធ្ងន់ធ្ងរដល់ដំណើរការផ្លាស់ប្តូរខ្យល់លើសរីរាង្គដកដង្ហើមរងទេ។

ប្រភេទត្រីមួយចំនួន អាចប្រើប្រាស់បាននូវកម្រិត អុកស៊ីសែន ក្នុងទឹកយ៉ាងតិច ឬកម្រិត កាបូនឌីអុកស៊ីត យ៉ាងច្រើន ដោយសារប្រភេទត្រី ទាំងនោះមានប្រព័ន្ធដកដង្ហើមរង ប្រព័ន្ធដកដង្ហើមរងមានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរស់នៅនិងលក្ខណៈបន្សាំខ្ពស់។

## ៤.១ ការដកដង្ហើមដោយពោះវៀន

ករណីក្នុងទឹកខ្វះ អុកស៊ីសែន ឬ កម្រិត កាបូនឌីអុកស៊ីត ច្រើន មានប្រភេទត្រីមួយចំនួនក្នុងអំបូរ Cobitis តែងងើបយកខ្យល់។ ខ្យល់បានបណ្ដូរ នៅពោះវៀនផ្នែកខាងក្រោយ និងខ្យល់ដែលសេសសល់បានបញ្ចេញតាមរន្ធបញ្ចេញចោល។

ពោះវៀនត្រី *Cobitis Fossilis* មានទម្រង់លក្ខណៈពិសេសជាង ត្រីប្រភេទដ៏ទៃទៀត ពោះវៀនផ្នែកមុខមានមុខងាររំលាយអាហារ ពោះវៀនផ្នែកក្រោយជាធម្មតាគ្មានចំណីអាហារ ភ្នាសរបស់ពោះវៀនមាន Capillary ក្រាស់កកើតដោយកោសិកាពីរះ មួយមានមុខងារផ្លាស់ប្ដូរខ្យល់ដកដង្ហើម មួយទៀតមានមុខងារបញ្ចេញសារជាតុរំអិល ដើម្បីជម្រុញចំណីអាហារ និងកាកសំណល់។ ក្នុងករណី កោសិកាបញ្ចេញសារជាតុរំអិលខ្លាំងក្លា នោះការដកដង្ហើមរបស់ពោះវៀនមានលក្ខណៈពិបាក ត្រីមានលក្ខណៈ Oppressive ដើម្បីទប់ទល់នឹងលក្ខណៈនេះ Erythrocyte នឹងកើនពី 2-7 លាន/mm$^3$ និង Hb ពី 4%ទៅ 22%។ នៅពេលកោសិកាបញ្ចេញសារជាតុរំអិលបានរលាយបាត់បង់មុចងារនោះ ឈាមប្រែជាមានសកម្មភាពធម្មតាវិញ(ដឹកនាំ អុកស៊ីសែន និង កាបូនឌីអុកស៊ីត )។ ខួបនៃការកកើតនេះមាន រយៈពេល 24-45 ម៉ោង។

## ៤.២ ការដកដង្ហើមដោយស្បែក

កកើតតែចំពោះប្រភេទត្រីដែល គ្មានស្រកា និងស្រកាតិចដូចជាៈ Anguillidae Blenniidae, Gobudae, Sulirdae។ ស្បែកមានទម្រង់ពិសេស ផ្នែកក្រៅនៃស្បែកមានតួនាទីផ្លាស់ប្ដូរខ្យល់បានយ៉ាងងាយស្រួល។ ផ្អែកលើមជ្ឈដ្ឋានរស់នៅ និងកម្រិតដកដង្ហើមនៃស្បែក នោះបែងចែកត្រីជាបីប្រភេទ៖

+ **ត្រីរស់នៅមជ្ឈដ្ឋានជានិច្ចជាកាលខ្វះ អុកស៊ីសែន**

នៅពេលបណ្ដាសារជាតុសរីរាង្គបម្លែងយ៉ាងខ្លាំងក្លា នោះការដកដង្ហើមដោយស្បែកមានដល់ 17-31% នៃកម្រិតដកដង្ហើមសរុបដូចជាៈ ត្រីអណ្ដែង អន្ទង់ ត្រី Particular មានពេលខ្លះការដកដង្ហើមដោយស្បែកមានរហូតដល់ 35% ។

+ **ត្រីរស់នៅមជ្ឈដ្ឋានខ្វះ អុកស៊ីសែន ជាមធ្យម**

ការដកដង្ហើមដោយស្បែកមានពី 9-12% ដូចជាត្រី *A.Acopemcer* ( Sturgeon )។

+ **ត្រីរស់នៅមជ្ឈដ្ឋានមាន អុកស៊ីសែន គ្រប់គ្រាន់**

ដំណើរការដកដង្ហើមដោយស្បែកមានពី 3-9% ដូចជាត្រី *Lates calcarifer* (Perch)ត្រី Salmon ការដកដង្ហើមតាមស្បែកប្រព្រឹត្តទៅជាធម្មតា លុះត្រាតែជានាស្បែកឱ្យសើម។

## ៤.៣ ការដកដង្ហើមដោយសរីរាង្គលើស្រកី( ទម្រង់ដូចផ្កាស្ពី )

សរីរាង្គដកដង្ហើមរងលើស្រកីមានទម្រង់ជាច្រើនដូចជាៈ ត្រីក្រាញ់ ត្រីរ៉ស់ ត្រីអណ្តែង...។ល។ ស្រកី និងសរីរាង្គដកដង្ហើមរង មានទំនាក់ទំនងជំនួយគ្នាទៅវិញទៅមក ប្រសិនបើរាំងស្កាត់ផ្នែកណាមួយនៃសរីរាង្គដកដង្ហើមនោះ នាំឱ្យងាប់ ដូចជា ត្រីរ៉ស់ ត្រីឆ្តោ...។ល។ (រស់នៅក្នុងមជ្ឈដ្ឋានសម្បូរ អុកស៊ីសែន ប៉ុន្តែមិនអាចធ្វើការដកដង្ហើមនៅក្នុងបរិយាកាសបាននោះវានឹងងាប់)។

### ៤.៤ ការដកដង្ហើមដោយសួត

សួតរបស់ត្រីកកើតឡើងដោយការវិវត្តន៍របស់ផ្លោកខ្យល់បង្កើតឡើង។

ក្នុងករណី មជ្ឈដ្ឋានរស់នៅមាន អុកស៊ីសែន គ្រប់គ្រាន់នោះការដកដង្ហើមអាស្រ័យដោយស្រកី ពេល អុកស៊ីសែនថយចុះឬមជ្ឈដ្ឋានប្រែជាគោកនោះ វាដំណើរការដកដង្ហើមដោយសួត ត្រី Caratodus ក្នុងរយៈពេល ៤០-៥០ នាទីងើបដកដង្ហើមបរិយាកាស។ ត្រី Lepidosiren និងត្រី Protopterus ឈ្មុលចូលក្នុងភក់បញ្ចេញសារធាតុ Slimy រុំព័ន្ធខ្លួនបម្លែងទៅជាសភាពលក្ខណៈក្រាំង ពេលនោះវាដកដង្ហើមដោយសួត។

## ៥. ទម្រង់របស់ផ្លោកខ្យល់

ភាគច្រើនមានប្លោកខ្យល់នៅខាងក្រោមឆ្អឹងខ្នង។ ប្លោកខ្យល់នេះមានទម្រង់ជាថង់មានខ្យល់នៅខាងក្នុង។ ចំពោះត្រីភាគច្រើន ប្លោកខ្យល់មាននាទីធ្វើឱ្យត្រីអណ្តែតដែលអាចឱ្យត្រីបណ្តែតខ្លួននៅក្នុងជម្រៅទឹកដែលវាត្រូវការ។ ចំពោះត្រី Dipnoi (lungfish:ត្រីមានសួត( និងត្រីមួយចំនួនតូចផ្សេងទៀត ប្លោកខ្យល់ត្រូវបានប្រើជាសួតសម្រាប់ដកដង្ហើម។ នៅមានត្រីផ្សេងទៀតរួមមានត្រីឆ្លាង ត្រីកញ្ចុះ ត្រីអណ្តែង ប្រើប្រាស់ប្លោកខ្យល់របស់វាសម្រាប់បញ្ចេញសម្លេង និងសម្រាប់បណ្តែតខ្លួនផងដែរ ។ ប្រភេទត្រីខ្លះទាក់ទងគ្នា ដោយសម្លេងទាំងនោះ ។

ត្រីអាចនឹងលិចចុះទៅបាតទឹក ប្រសិនបើវាគ្មានមធ្យោបាយរក្សាលំនឹងបណ្តែតខ្លួនឯង។ ត្រីភាគច្រើនបណ្តែតខ្លួនដោយសារការបំប៉ោងប្លោកខ្យល់របស់វាដោយខ្យល់ផលិតដោយឈាមរបស់វា។ ប៉ុន្តែសំពាធ ទឹកកើនឡើងស្របគ្នានឹងជម្រៅទឹក។ កាលណាត្រីហែលចុះក្នុងទឹកជ្រៅ សម្ពាធទឹកកើនឡើងធ្វើឱ្យប្លោក ខ្យល់របស់វារួមតូចនិងបន្ថយកម្រិតអណ្តែតរបស់ត្រីផងដែរ។ បរិមាណឧស្ម័ននៅក្នុងប្លោកខ្យល់ត្រូវតែត្រូវបានបង្កើន ដែលប្លោកខ្យល់នៅតែធំល្មមអាចរក្សាកម្រិតអណ្តែតរបស់ត្រីបាន។ ប្រព័ន្ធប្រសាទត្រីកម្រិតដោយ ស្វ័យប្រវត្តនូវបរិមាណឧស្ម័នក្នុងប្លោកខ្យល់ ដែលត្រូវបានបំពេញដោយត្រឹមត្រូវ ។ ភ្លាមនិងបបែលគ្មានប្លោក ខ្យល់ទេ ។ ដើម្បីឱ្យខ្លួនវាអណ្តែត ត្រីទាំងនេះត្រូវតែហែលជាប់ជានិច្ច។ ពេលវាសំរាក វាឈប់ហែល ខ្លួន វាលិចចុះទៅបាតទឹក ។ ប្រភេទត្រីឆ្អឹងជាច្រើនដែលរស់នៅបាតទឹកក៏គ្មានប្លោកខ្យល់ដែរ ។

សរីរាង្គប្លោកខ្យល់ត្រីឆ្អឹងរឹង ស្ថិតនៅចន្លោះបំពង់រំលាយអាហារ និងតម្រងនោម ដែលមានផ្ទុកអុកស៊ីសែន, កាបូនឌីអុកស៊ីត និង $N_2$ ជាធម្មតាមានសមាត្រផ្សេងៗគ្នា ទៅតាមសមាត្រខ្យល់ ក្នុងបរិយាកាសជុំវិញ។

ប្លោកខ្យល់ត្រីឆ្អឹងរឹងមានលក្ខណៈពីរយ៉ាង៖

### ៥.១ ប្លោកខ្យល់បើក

មានបំពង់ភ្ជាប់ទៅនឹង Oesophagus ដូចជាក្នុងអំបូរត្រី Cyprinidae និងអំបូរត្រីកាដិច គ្មានបំពង់ភ្ជាប់ទៅ Oesophagus តែមានបំពង់តភ្ជាប់ទៅរន្ធបញ្ចេញចោល។

### ៥.២ ប្លោកខ្យល់បិទ

គ្មានបំពង់តភ្ជាប់ទៅ Oesophagus តែមានប្រព័ន្ធសរសៃឈាមបន្តជាប់ជាមួយ។

ប្លោកខ្យល់របស់ *Anguilla Anghilla* មានទម្រង់ ជាលក្ខណៈរួមនៃ **ប្លោកខ្យល់បើក និង បិទ** (Slightly Open និង Tight )។ ក្រៅពីដកដង្ហើម ប្លោកខ្យល់មានមុខងាររក្សាលំនឹង និងបញ្ចេញសូរសំឡេង ដោយសារប្រព័ន្ធសរសៃវិញ្ញាណឆ្អឹងខ្នង។

## ៦. មុខងាររបស់ ប្លោកខ្យល់

### ៦.១ មុខងារ Hydrostatics

ជាមុខងារមួយក្នុងចំណោមមុខងារសំខាន់របស់វា គឺជាសរីរាង្គ Hydrostatics ដោយរបៀបបង្កើនឬបន្ថយទម្ងន់ក្នុងមួយខ្នាតម៉ាសមាឌនៃសរីរាង្គ ដោយវាបង្កើតចេញនូវ ដង់ស៊ីតេរបស់ត្រីធំជាងឬតូចជាងមជ្ឈដ្ឋានរស់នៅរបស់វា។

ជារួមមានលក្ខណៈបីយ៉ាងដើម្បីសម្រាយបញ្ជាក់មុខងារHydrostatics៖

+ ត្រីដែលមានប្លោកខ្យល់វិវត្តន៍នោះ ការហែល ឬការធ្វើចលនាបានយ៉ាងងាយស្រួលនៅតាមស្រទាប់ទឹកកណ្តាល ផ្ទុយនឹងត្រីមានប្លោកខ្យល់តូច ឬវិវត្តន៍កម្រិតទាប។

+ បណ្តាលមេគុណដង់ស៊ីតេឱ្យយើងដឹងកត្តាលិច(មុជចុះ) Lowender, 1937 បាន Reverse ជា 1000(Ex: ដង់ស៊ីតេទឹក=1,000)ត្រីមានដង់ស៊ីតេ=0,991 នោះកត្តាមុជ $1000\times0,991=991$។

  ចំពោះត្រីទឹកសាបប្លោកខ្យល់មានសមាមាត្រ 7-10% នៃមាឌសរុប និងប្រហែល 5% ចំពោះត្រីទឹកប្រៃ។ នេះ ជា %នៃមាឌចាំបាច់របស់ប្លោកខ្យល់មានមុខងារHydrostatics។

  តាម Taylor, 1921 and Jones, 1951 ក្នុងពេលប្លោកខ្យល់តូច ឬគ្មាននោះ កត្តាលិចនឹងមានលក្ខណៈខ្លាំងក្លាជាច្រើនដង។

+ ត្រីត្រូវបំពេញ(Balance) ឬ បន្ថយបានធ្វើឱ្យដង់ស៊ីតេប្រែប្រួលដោយការថយចុះ ឬកើនឡើងមាឌប្លោកខ្យល់ ដែលកកើតឡើងក្នុងពេលត្រីធ្វើចលនាពីជម្រៅជ្រៅឡើងមកស្រទាប់លើផ្សេងទៀត។ ការបំពេញ បន្ថយរបស់ប្លោកខ្យល់ បានត្រូវសម្តែងចេញដោយការបញ្ចេញចោលខ្យល់ ឬបញ្ជូនខ្យល់។

## ក/ ការបញ្ចេញខ្យល់

❖ អុកស៊ីសែន និង កាបូនឌីអុកស៊ីត

ការបញ្ចេញខ្យល់អាចរំញោចបានដោយរបៀបពិសោធន៍ការកើនសម្ពាធ Hydrostatic ឬការធ្វើអំពើទៅលើទម្ងន់នៃសារពាង្គកាយត្រី(Extand)។ ប្រសិនបើការបញ្ចេញខ្យល់ដោយអំពើបំបាត់ចោលខ្យល់ពីក្នុងប្លោកខ្យល់ ខ្យល់ដែលបានប្តូរដំបូងមាន កាបូនឌីអុកស៊ីត ច្រើន បន្ទាប់មក អុកស៊ីសែន បានកើតឡើងនៃសមាមាត្រជាច្រើន។

តាម Copeland, 1952 ក្នុងការបញ្ចេញខ្យល់នោះសកម្មភាព Metabolism កើន តែ Glucogen បានថយចុះ ការបម្លែង Glucogen កើតចេញពី a lactic នេះប្រហែលជាប្រភពបង្កើត កាបូនឌីអុកស៊ីត ចូលក្នុងប្លោកខ្យល់ និង កាបូនឌីអុកស៊ីត អាច កកើតមានឡើងពីអាស៊ីតខាងលើ ដោយ Bicabonat ក្នុងឈាម Erythrocyte Carbonic Anydrate បញ្ជាក់ឱ្យឃើញថា មានមុខងារសំខាន់ក្នុងការបញ្ចេញខ្យល់។ ការចាក់បញ្ចូលក្នុងជាលិកានូវសារជាតុរំញោចមិនសមស្រប ដោយបម្លែង Erythrocyte Carbonic Anydrate នោះនឹងធ្វើឱ្យកាត់ផ្តាច់ការបញ្ចេញខ្យល់ ការបង្កើតចេញ កាបូនឌីអុកស៊ីត ក្នុងជាលិកានៃក្រពេញប្លោកខ្យល់ និងធ្វើឱ្យថយចុះ pH នៃឈាម ធ្វើឱ្យ Hbអុកស៊ីសែន ផ្តាច់អុកស៊ីសែន យ៉ាងងាយស្រួល។

- $N_2$: តាម Power, 1932 ឱ្យដឹងថា សម្ពាធ $N_2$ ខ្ពស់ក្នុងប្លោកខ្យល់ អាស្រ័យដោយ $N_2$ រលាយក្នុងខ្យល់។ កាបូនឌីអុកស៊ីត, អុកស៊ីសែន បានបង្កើតឡើងក្នុងក្រពេញប្លោកខ្យល់ និងនៅពេលដែល កាបូនឌីអុកស៊ីត, អុកស៊ីសែន រលាយបាត់ នោះ $N_2$ នឹងចូលក្នុងប្លោកខ្យល់ដោយមិនអាស្រ័យដោយសម្ពាធរបស់ប្លោកខ្យល់ឡើយ។

## ខ/ ការស្រូបយក

ការស្រូបយកខ្យល់កកើតឡើងពេលដង់ស៊ីតេរបស់ត្រីត្រូវថយចុះបណ្តាលឱ្យត្រីងើបឡើងផ្ទៃទឹក។ ពេលបញ្ចូលខ្យល់ក្នុងប្លោកខ្យល់ ឬមានអំពើណាមួយធ្វើឱ្យថយចុះសម្ពាធ Hydrostatics នោះការស្រូបយកខ្យល់អាចរងនូវការរំញោចដោយការថប់ដង្ហើម (Coppressive) ពេលនោះការស្រូបយកកកើតឡើងយ៉ាងរហ័សនៅពេលដែលកម្រិត កាបូនឌីអុកស៊ីត ដើមដំបូងមានច្រើនក្នុងប្លោកខ្យល់ និង Mechanism របស់វាមានតែមួយគត់។

ចំពោះត្រីមានប្លោកខ្យល់ Slightly Openការរំដោះខ្យល់មានងាយបំផុត ខ្យល់ដែលចេញពីប្លោកខ្យល់ឆ្លងកាត់បំពង់តភ្ជាប់ អាស្រ័យដោយសកម្មភាពកន្ត្រាក់នៃសាច់ដុំកង
នៃបំពង់តភ្ជាប់ រុញចូលទៅក្នុងបំពង់អាហារ និង បញ្ចេញមកក្រៅតាមះ មាត់ ស្រកី រន្ធបញ្ចេញចោល។

## ៦.២ មុខងារដកដង្ហើម

### ក/ ប្លោកខ្យល់ដូចជាសួត

ប្លោកខ្យល់ Slightly Open មួយចំនួនអាចមានមុខងារដូចជា សួត ប្រភេទត្រីដូចនេះ តែងរស់នៅមជ្ឈដ្ឋានជានិច្ចកាលមាន Pកាបូនឌីអុកស៊ីត ច្រើន និង កម្រិត Pអុកស៊ីសែន យ៉ាងតិច។

### ខ/ ប្លោកខ្យល់ដូចជាឃ្លាំងផ្ទុក អុកស៊ីសែន (ស្តុកអុកស៊ីសែន)

ត្រីមានប្លោកខ្យល់ Slightly Open និង Tight ដែលមិនមានមុខងារដូចសួត អាចបម្រុងផ្ទុក អុកស៊ីសែន ក្នុងប្លោកខ្យល់ដូចឃ្លាំង(Store) ដែលអាចផ្ទុកក្នុងរយៈពេលខ្លី។ តាម Hall,1924 and Khali, 1937 កំណត់ឃើញ អុកស៊ីសែន ក្នុងប្លោកខ្យល់អាចដោះស្រាយនូវតម្រូវការប្រើប្រាស់ អុកស៊ីសែន ជាច្រើននាទីបាន។

## ៦.៣ មុខងារទទួលអារម្មណ៍

### ក/ មុខងារទទួលអារម្មណ៍នៃភ្នាសប្លោកខ្យល់

តាម Baglioni, 1908 កំណត់ថា ប្លោកខ្យល់មានមុខងារដូចសរីរាង្គទទួលរំញោច ជួយឱ្យត្រីយល់ដឹងសមស្របសម្ពាធ (Preserve) នៅកម្រិតជម្រៅកំណត់មួយ ក្នុងការរស់នៅក្នុងស្រទាប់ទឹក ប្រសិនបើត្រីហែលនៅ ស្រទាប់លើ ឬ ក្រោមជម្រៅកំណត់ក្នុងការរស់នៅ ដែលនៅទីនោះវាមានលំនឹង Hydrostatics ប៉ុន្តែប្រែប្រួលកម្លាំងលំនឹងរឹងមាំនៃភ្នាសប្លោកខ្យល់ នេះបណ្តាលមកពីការបន្ទូរ ឬ បញ្ចូលខ្យល់ ធ្វើឱ្យត្រីអាចត្រឡប់ទៅកម្រិតជម្រៅរស់នៅក្នុងស្រទាប់ទឹករបស់វា។

តាម Dij Kgraaf កំណត់ថា៖ ប្រភេទនៃប្លោកខ្យល់(ប្លោកខ្យល់Slightly Open) មានលក្ខណៈទទួលអារម្មណ៍ឯកឯង ដោយភ្នាសនៃប្លោកខ្យល់មានអំពើ ដល់ដំណើរការដោះស្រាយខ្យល់។

### ខ/ មុខងារទទួលអារម្មណ៍ដែលមានទំនាក់ទំនងជាមួយត្រចៀក

- **ការទទួលនូវកម្លាំងសម្ពាធដោយឆ្អឹង Weber**

ចំពោះត្រី Ostariophsis ផ្នែកមុខនៃបំពង់ខ្យល់ បានភ្ជាប់ជាមួយផ្នែកមុខនៃត្រចៀក ដោយឆ្លងកាត់ឆ្អឹង weber។

តាម Brigdl and Hoddon, 1893 កំណត់ថា Mechanism នេះបង្កើនការទទួលអារម្មណ៍របស់ត្រី ជាមួយការប្រែប្រួលមាឌនៃប្លោកខ្យល់ និងមានការពិនិត្យសម្រួលយ៉ាងច្បាស់លាស់ ក្នុងការរំដោះ

ខ្យល់ឆ្លងកាត់បំពង់ Oesphagus នៅពេលបានសម្រាំងជម្រើសនៃការប្រែប្រួល ជាមួយនឹងការថយចុះជាសន្សឹមៗនៃកម្លាំងសម្ពាធ។

Ex: ត្រី Minnow បានរំដោះខ្យល់ នៅពេលដែលកម្លាំងសម្ពាធថយចុះដល់ 32mm/Hg ។

Tresholt នេះ កើនឡើងដល់ 39mm/Hgក្រោយពេលត្រីត្រូវខូចខាតឆ្អឹង Marrow តភ្ជាប់រវាងប្លោកខ្យល់ និង ផ្នែកក្រោមនៃត្រចៀក។

❖ **មុខងារស្តាប់សូរសំឡេង(Hearing) ជាមួយទំនាក់ទំនងត្រចៀក**

គេបានកំណត់ថាប្លោកខ្យល់របស់ត្រីមានទំនាក់ទំនងជាមួយផ្នែកក្រោមរបស់ត្រចៀកដោយសារឆ្អឹង weber និងថង់នៃប្លោកខ្យល់ ដែលអាចឆ្លើយតបជាមួយនឹងសូរសំឡេង Frequency មាន ខ្ពស់ និអ សូរសំឡេងមាន Frequency តិច ចំពោះប្រភេទត្រី ដែលប្លោកខ្យល់គ្មានទំនាក់ទំនងជាមួយឆ្អឹងត្រចៀក។

Ex: ត្រីជៀវ(Thieu)អាចឆ្លើយតបជាមួយ Frequency ពី 16.000 – 7.000cps(មួយខួបក្នុងរយៈពេលមួយវិនាទី) ក្នុងករណីកាត់ចោលផ្នែកក្រោមទាំងពីរនៃត្រចៀកនោះ ត្រីទទួលនូវ Frequency មិនលើសពី 100-150cpsប៉ុន្តែ មិនធ្វើឱ្យខូចត្រចៀក។ ពេលបំបាត់ចោលប្លោកខ្យល់នោះ Frequency ដែលទទួលបានមិនលើសពី2600cps។

## ៦.៤ មុខងារបញ្ចេញសូរសំឡេង

គេបានដឹងថា ប្លោកខ្យល់មានុខងារសំខាន់ក្នុងការបង្កើតឡើងនូវសូរសំឡេង។ សូរសំឡេងនោះងាស្រ័យដោយប្លោកខ្យល់បញ្ចេញដោយផ្ទាល់មួយផ្នែក និងមួយផ្នែកទៀត ការបញ្ចេញសូរសំឡេងដោយសារខ្យល់ក្នុងបំពង់បន្តពីប្លោកខ្យល់មកភ្ជាប់ Oesphagus បង្កើតឡើងដោយសារការកន្ទ្រាក់នៃសាច់ដុំពិសេសផ្ទាល់។

សូរសំឡេងដែលបានបញ្ចេញដោយ ប្រភេទត្រីទាំងនោះនៅរដូវបន្តពូជមានសារៈសំខាន់បំផុត ដូចជាការរកដៃគូរបន្តពូជ...។ល។ ក្រៅពីនេះសូរសំឡេងមានលក្ខណៈក្នុងការសម្រុកក្នុងការធ្វើចលនា ឬសំឡុតបង្អាក់សកម្មភាពសត្រូវប្រភេទត្រីជាច្រើនភេទឈ្មោលបញ្ចេញសូរសំឡេងខ្លាំងក្លាជាងភេទញី។

# មេរៀនទី៥
# សរីររំលាយអាហារនិងការស្រូបយកសារធាតុចិញ្ចឹម

## ១. ផ្នែករំលាយអាហារ

រំលាយអាហារជាដំណើរការបម្លែងបណ្តាសារធាតុចិញ្ចឹម មានទម្រង់សាំញ៉ាំ ទៅជាសារធាតុចិញ្ចឹមមានទម្រង់សាមញ្ញដែលសរីរាង្គអាចស្រូបយកបានពីក្នុងបំពង់រំលាយអាហារ។ រំលាយអាហារជាចំណែកមួយក្នុងដំណើរការផ្លាស់ប្តូរសារធាតុជាមួយនឹងមជ្ឈដ្ឋានខាងក្រៅ ផ្អែកលើដំណើរការរំលាយទើប សរីរាង្គស្រូបយកសារធាតុចិញ្ចឹម ជាដំបូងជម្រុញឱ្យសរីរាង្គលូតលាស់ធំធាត់ និងផ្តល់ថាមពលចាំបាច់សម្រាប់សរីរាង្គធ្វើសកម្មភាព។

### ១.១ ប្រព័ន្ធរំលាយអាហារ

#### ក/ ប្រព័ន្ធសរីរាង្គរំលាយអាហារ

ប្រព័ន្ធរំលាយអាហាររបស់ត្រីបានចែកជា ច្រើនផ្នែក និង មានមុខងារផ្សេងៗ៖

❖ ផ្នែកទទួល

នៅផ្នែកនេះមានសរីរាង្គទទួលអារម្មណ៍ ដែលជួយក្នុងការរាវរកចំណី ការជ្រើសរើសចំណីអាហារចំពោះត្រីផ្នែកនេះគ្មានអង់ស៊ីមរំលាយអាហារទេ។

❖ ផ្នែកដឹកនាំ

ចាប់ពី Oespgagus នៅផ្នែកនេះមានក្រពេញរំលាយអាហារមួយចំនួនខ្លះតែប៉ុណ្ណោះ។

❖ ផ្នែកចាប់ផ្តើមការរំលាយអាហារ ឬកិនរំលាយ

ស្ថិតក្នុងផ្នែកនៃក្រពះ អង់ស៊ីមរំលាយអាហារ ដែលបញ្ចេញទៅក្នុងក្រពះ ដោយជាលិកានៃក្រពេញរំលាយអាហាររួម ដែលស្ថិតក្នុងក្រពះ ឬពីCaecum ។

❖ ផ្នែករំលាយអាហារចុងបញ្ចប់ និង ការស្រូបយកសារធាតុចិញ្ចឹម

ស្ថិតក្នុងពោះវៀនមុខ ឬពោះវៀនកណ្តាល ការរំលាយអាហារអាចបន្ត ដោយប្រើប្រាស់អង់ស៊ីមដែលសេសសល់ ឬក្រពេញរំលាយ នៃលំពែង ប្រម៉ាត់។ ចំណីអាហារក្រោយពេលរំលាយត្រូវបានស្រូបយកជាសារធាតុចិញ្ចឹម។

❖ ផ្នែកបង្កើតកាកសំណល់

ស្ថិតក្នុងពោះវៀនផ្នែកក្រោយ។

#### ខ/ ទម្រង់មាត់ និង Qesophagus

ទីតាំង ទម្រង់ ទំហំនៃប្រម៉ាត់ របស់ត្រីផ្សេងៗគ្នា ព្រមទាំងមានទំនាក់ទំនងទៅនឹង មុខងារ ចរឹកលក្ខណៈ និងចាប់ចំណី...។

ត្រីដែលស៊ីចំណីមានលក្ខណៈប្រោះ ដូចជា ត្រីកាប ត្រី *Ospgronemus goramh*មាត់មានលក្ខណៈងើបឡើងលើបន្តិច ប្រភេទត្រីដែលស៊ីចំណីនៅផ្នែកក្រោម ដូចជា ត្រៅកាបសាមញ្ញ មាត់មានលក្ខណៈចុះក្រោមបន្តិច។

ទម្រង់របស់ឆ្អឹង Xillare នៃត្រីឆ្អឹងរឹងមានលក្ខណៈសាំញ៉ាំបង្គួរជាមួយលក្ខណៈនៃធ្មេញត្រីដុះចេញ។

ធ្មេញត្រីមានលក្ខណៈដូចជាធ្មេញសត្វកម្រិតខ្ពស់ដែរ(ត្រី) ត្រីឆ្អឹងទន់ធ្មេញដុះលើ Os xillareដែលអាស្រ័យដោយបន្ទះ Scales ប្រែប្រួលបង្កើតឡើង ធ្មេញត្រីឆ្អឹងរឹងដុះលើ Os xillare លើ និងក្រោម។ មានប្រភេទត្រីខ្លះធ្មេញដុះលើអណ្តាត និងដុះលើឆ្អឹង Os xillare របៀបដុះនៃធ្មេញ និងទម្រង់នៃធ្មេញមានលក្ខណៈផ្សេងៗគ្នាទៅតាម សភាពលក្ខណៈនៃត្រីដូចជាៈ

-ត្រីរ៉ស់ ស៊ីសាច់ ធ្មេញមានលក្ខណៈវែងនិងស្រួច(canines)។ ការប្រើប្រាស់ធ្មេញជាសំខាន់គឺចាប់ចំណី ឬខាំ ធ្មេញគ្មានមុខងារទំពារចំណីទេ។ ត្រី Hold Pharyngo (ត្រីឆ្អឹងរឹង) មានធ្មេញ Pharyngo លើ និងក្រោម អាចផ្តាច់ចំណីអាហារបាន ដោយគ្រាន់តែធ្វើឱ្យប្រែប្រួលទម្រង់នៃចំណីពោលគឺមិនមែនទំពារលំអិតចំណី។

-ធ្មេញ Paryngo ទម្ង់ជាស្និតរបស់ត្រីកាបស៊ីស្មៅ និងប្រភេទត្រីផ្សេងទៀតអាចខាំផ្តាច់សំបកការពារនៃពពួកសត្វសក និងសត្វមានខ្លួនទន់តូច។

ត្រីស៊ីពពួក គ្មានធ្មេញទេ ដូចជាត្រីកាប ប៉ុន្តែស្និតស្រកីលូតលាស់ខ្លាំង (តូចល្អិតរាងវែងនិងចំនួយយ៉ាងច្រើន)ចំណីអាហារនាំតាមទឹកចូលតាមមាត់ត្រូវបានច្រោះដោយតម្រងស្រកី(Gilracker) ក្រោយមកទើបលេបបញ្ចូលឆ្លងកាត់ Oesophagus។

ក្នុងក្រអូមមាត់ត្រី Petromyzon គ្មានសរីរាង្គរំលាយអាហារ(រស់ដោយមាត់សម្រាប់ជប់)ក្នុងមាត់តែក្រពេញបញ្ចេញសារជាតុទប់ទល់នូវការកកឈាម ខ្លះទៀតក្រអូមមាត់មានតែកោសិកាបញ្ចេញសារជាតុរំអិលធ្វើឱ្យចំណីអាហាររងាយលេបចូលទៅក្នុង។ ត្រីភាគច្រើន Oesophagus ខ្លីបំផុត។ ដែនកំណត់នៃ Oesophagus និងក្រពះមិនច្បាស់លាស់ លើសពីនេះទៀតផ្នត់ក្រពះមានប្រវែងវែងរហូតដល់ Oesophagus ដូចនេះ គេអាចកំណត់ថា Oesophagus គឺជាផ្នែកដើមដំបូងនៃក្រពះ ប៉ុន្តែបើពិនិត្យមើលចំណាំងតាំងសាស្ត្ររវាង Oesophagus និងក្រពះមានមុខងារលក្ខណៈខុសគ្នាទាំងស្រុង។

Oesophagus ក៏ដូចជាក្រអូមមាត់ មានតែមួយស្រទាប់កោសិកា Epiderm, Oesophagus មានមុខងាររុញច្រានចំណីអាហារគ្មានមុខងាររំលាយអាហារទេ។

**គ/ ក្រពះ**

ប្រភេទត្រីមួយចំនួនគ្មានក្រពះ ដូចត្រីកាបសាមញ្ញ ផ្នែកបន្តពី Oesophagus រីកប៉ោងហៅថាផ្នែកពោះវៀនដោយគ្មានសារជាតុក្រពេញរបស់ក្រពះ។

តាមទម្រង់របស់ក្រពះ គេចែកក្រពះជាច្រើនទម្រង់ដូចជា ពពួកត្រីកាចក្រពះមានរាង V U I ប្រភេទត្រីមួយចំនួនក្រពះអាចចែកជាផ្នែកដូចជា ក្រពះត្រីដែរ ក្នុងពេល ស៊ីចំណី ឬផឹកទឹក មាឌក្រពះកើនឡើងប៉ុន្តែមិនធ្វើឱ្យកម្លាំងសម្ពាធក្នុងក្រពះកើនទេ។ ក្រពះ ជាប្លោកទទួល ឬបញ្ចេញចំណីទៅក្នុងពោះវៀន និងជាកន្លែងរំលាយអាហារ។ ដូចនេះក្រពះមានសកម្មភាពដូចជា Store ចំណីងអាហារ និង Harmonize ចំណីអាហារ រួចបានរំលាយនាំចូលទៅក្នុងពោះវៀន។

### ឃ/ ពោះវៀន

ពោះវៀនជាសរីរាង្គ តភ្ជាប់ពីក្រពះ ឬ ពី Oesphagus បន្តទៅដល់រន្ធបញ្ចេញចោល វាជាផ្នែកមួយសម្រាប់ទទួលយកអាហារ ដែលកិនលំអិតពីក្រពះ និង កាកសំណល់ផ្សេងៗទៀតបញ្ចេញមកក្រៅ។ ពោះវៀនត្រីមានប្រវែងវែង ឬ ខ្លី អាស្រ័យតាមប្រភេទត្រី។

ប្រវែងពោះវៀនប្រៀបធៀបជាមួយប្រវែងដងខ្លួន ដើម្បីដឹងអំពីចរឹកស៊ីចំណីរបស់ប្រភេទត្រីនីមួយៗ។

តាមលោក Licrcku, 1963 បានកំណត់ចរឹកស៊ីចំណីរបស់ប្រភេទត្រីតាមផលធៀបខាងក្រោម៖

ប្រវែងពោះវៀនសរុប ចែកឱ្យប្រវែងដងខ្លួន (Li ចែកឱ្យLt)

-ត្រីស៊ីសាចជាអាហារ= Li/lt≤1

-ត្រីស៊ីចម្រុះ=Li/Lt≥3

-ត្រីស៊ីចម្រុះតែមានលក្ខណៈសាច់=1≤Li/Lt≤3

## ១.២ ការរំលាយអាហារ

### ក/ មេកានិចរំលាយអាហារ

- មេកានិចរំលាយអាហាររបស់ក្រពះ

**-ក្រពះទទេ(Empty)៖** ករណីមិននស៊ីចំណីក្រពះរួមស្វិត កម្លាំងសម្ពាធក្នុងក្រពះប្រហាក់ប្រហែលកម្លាំងសម្ពាធក្នុងពោះវៀន ប្រភេទត្រីភាគច្រើន ក្នុងពេលខ្លះ ឬគ្មានពេលណាដែលក្រពះទទេទាំងស្រុងឡាយ។

**-ធ្វើឱ្យពេញក្រពះ៖** ពេលស៊ីចំណី ចំណីត្រូវបានចូលទៅក្នុងក្រពះដោយការរុញទាញរបស់សាច់ដុំនៃក្រពះ ក្រពះទាំងអាចធន់ នូវទម្ងន់របស់ចំណី ដោយគ្មានការកើនឡើងកម្លាំងសម្ពាធក្នុងក្រពះ។ ចំណីចូលទៅក្នុងក្រពះតំរៀបតាមលំដាប់ស្រទាប់ ពេលស៊ីចំណីចូលទៅ។ បន្ទាប់មកការកិនរំលាយនៃក្រពះនៅផ្នែកបាត និងផ្នែកពោះក្រពះ មិនអាចប្រព្រឹត្តឡើងភ្លាមៗឡើយ មានន័យថា ចំណីអាហារមិនទាន់បានប្រើប្រាស់ជាសារជាតុចិញ្ចឹមភ្លាមៗឡើយ។

**-ចលនារបស់ក្រពះ៖** ដោយសារសាច់ដុំរបស់ក្រពះ។ ក្នុងពេលស៊ីចំណី ចលនានៃក្រពះមិនងាយនឹងមានចលនា។ ពេលក្រពះមានចលននារុញច្រានចំណីអាហារដល់ផ្នែក្រោមក្រពះ នោះសាច់ដុំកង

មានចលនាបិទមិនឱ្យចំណីអាហារចេញ ចំណីអាហារត្រឡប់បញ្ច្រាស។ ចលនាពោះវៀនបន្តភ្ជាប់ជាមួយចលនាក្រពះផ្នែកក្រោម។

-**ការបញ្ចេញចំណីអាហារ៖** ក្រោយពេលច្របល់លាយ និងការរំលាយអាហារមកវាត្រូវបញ្ចេញក្រៅក្រពះល្បឿននៃការបញ្ចេញមកក្រៅអាស្រ័យទៅតាមលក្ខណៈនៃចំណីអាហារ លក្ខណៈរូប-គីមី លក្ខណៈរាវ និង ខាប់នៃចំណីអាហារ និងលក្ខណៈសារធាតុដែលមាននៅក្នុងក្រពះដូចជា៖ សម្ពាធអូស្មូសបរិមាណតិច ឬច្រើន pH....។ល។

❖ មេកានិចរំលាយអាហាររបស់ពោះវៀន

\+ **ចលនាជាផ្នត់ៗ៖** ជាចលនាសំខាន់បំផុតនៃពោះវៀន ចំណីអាហារត្រូវចែកជាចំណែកៗរាងជាពងក្រពើដោយការកន្ត្រាក់របស់ពោះវៀន។ ចលនានេះអាចធ្វើឱ្យចំណីអាហារ លាយច្របល់ជាមួយរសរំលាយអាហារ និងធ្វើឱ្យសារធាតុចិញ្ចឹមជួប(ប៉ះ) ផ្ទៃក្នុងនៃកោសិកាស្រូបយកសារធាតុចិញ្ចឹម។

\+ **ចលនាកន្ត្រាក់ច្របាច់** (Pendulum)**៖** ចំណីអាហារនៅផ្នែកនីមួយៗនៃពោះវៀនត្រូវបានច្របល់លាយជាមួយរស់រំលាយអហារ។

\+ **ចលនារលករំជួល(Peristaltic Motion)៖** គឺជា Mechanismសំខាន់ដើម្បីរុញច្រាន ចំណីអាហារមានលក្ខណៈរាវពាក់កណ្ដាលឱ្យមានចនលាទៅមុខ ខួបនៃចលនានេះមានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទនៃត្រីផ្សេងៗ ក្រោយពេលស៊ីចំណីចលនារបស់ពោះវៀន មានសារៈសំខាន់ក្នុងការច្របាច់លាយចំណី និងដឹកនាំចំណី។

**ខ/គីមីរំលាយអាហារ**

❖ គីមីរំលាយអាហាររបស់ក្រពះ

-**សមាសភាព និងអំពើរបស់ Gastric juice:** គឺជាសារធាតុដែលបញ្ចេញដោយស្រទាប់ជាលិកានៃក្រពះ វាគ្មានព៌ណ តែមានសារធាតុរំអិល ដែលមានពីរផ្នែកជាសំខាន់ មួយផ្នែកជាអាស៊ីត និង មួយផ្នែកទៀតជា Pepsin។

សមាសភាព Gastric juice ប្រែប្រួលទៅតាមកម្រិតបញ្ចេញនៃភ្នាសជាលិកាក្រពះ វាមានកម្រិតអាស៊ីតខ្លាំង ឬ ខ្សោយក្នុងពេលបញ្ចេញមកច្រើន ឬក្នុងពេលឃ្លាន។

ត្រីឆ្អឹងទន់អាចបញ្ចេញ HCl ដល់ 0,5%> ថនិកសត្វ(0,4 – 0,5%)។

\+ **អំពើរបស់ HCl:** HCl ត្រូវបានជាលិកាក្រពះបញ្ចេញដែលមានផ្ទុកអំបិល Na, K ។ ក្នុងការបញ្ចេញ HCl នោះ កាបូនឌីអុកស៊ីត មានមុខងារយ៉ាង Neutralize ផ្នែកក្នុងកោសិកា។

អាស៊ីតក្រពះមានអំពើបង្រាប ឬសម្លាប់មេរោគ សម្លាប់កោសិការស់នៅនៃចំណីអាហារ និងអាចរំដោះផ្ដាច់ Ca នៃចំណីអាហារ។ អាស៊ីតក្រពះសត្វមានឆ្អឹងកងខ្នង អាចរំញោចដល់ការស្រូបយក Fe បម្លែងបង្កើត Pepsinogene ទៅជា Pepsim គឺជាអង់ស៊ីម សំខាន់របស់ក្រពះ និងជម្រុញ pH ឱ្យមានសកម្មភាពអតិប្បរមា។

+ **អំពើនៃPepsin:** មានចំពោះសត្វឆ្អឹងកងខ្នង និងត្រីឆ្អឹងទន់។ ការប្រើប្រាស់ Pepsinស្ថិតក្នុងក្រពះ និង មជ្ឈដ្ឋានអាស៊ីតខ្លាំង ទើប Pepsinមានសកម្មភាព។ pHសមស្របដល់ Pepsin1,75ទៅ 3 សីតុណ្ហភាពពី 30 -50 $^{0}$C។ Pepsinគឺជាអង់ស៊ីមសំខាន់ក្នុងការបម្លែង Proteinនិងមានអំពើបម្លែងបង្កើត Pepsinogene ។

អំពើសំខាន់នៃ Pepsim គឺបម្លែងសមាសធាតុ Protid ក្នុងចំណីអាហារទៅជា Protease និង Pepton សមិទ្ធិផលនេះចូលទៅពោះវៀន ដើម្បីបំបែកបម្លែងសារធាតុ។

+ **ប្រភេទអង់ស៊ីមផ្សេងៗ៖** អ្នកស្រាវជ្រាវមួយចំនួនដូចជា៖ Palamani and Mackay, 1929 ស្រាវជ្រាវលើត្រីឆ្អឹងទន់ និងឆ្អឹងរឹង រកឃើញអង់ស៊ីមបម្លែងសារជាតុម្សៅ(amylase and Lapase) ប៉ុន្តែពិននិត្យជារួមភាគច្រើនក្នុងក្រពះត្រីមិនមានLipase។ ប្រភេទត្រីផ្សេងគ្នា នោះលក្ខណៈអង់ស៊ីមផ្សេងគ្នាដែរ។ ក្រៅពី Pepsin នៅមាន glucogen, Cathepsin, Tripeptidase និង Dipeptidase ចំណែកឯប្រភេទដែលគ្មានក្រពះ ឬទោះមានទ្រង់ទ្រាយដូចជាក្រពះ ប៉ុន្តែមិនបញ្ចេញរស់ក្រពះ(tric juiceGas) មានលក្ខណៈអាស៊ីតនោះ ក្នុងនោះ គ្មាន pepsin កកើតទេ។

*ឆ្លងតាមការរំលាយអាហារក្នុងក្រពះត្រីប្រៀបធៀបជាមួយ ថនិកសត្វ នោះមានលក្ខណៈផ្សេងគ្នា ដូចជា៖

- សីតុណ្ហភាពសមស្របរបស់Pepsinទាប
- pH នៃ Pepsin ខ្ពស់ (ថនិកសត្វ pH=2 -2,4 ត្រី pH= 4,5 – 4,7)
- ក្នុងដំណើរការរំលាយអាហារ pH មានការប្រែប្រួលជាច្រើន ដូចជាត្រី salmon ថ្ងៃទី១ pH=3,1, ថ្ងៃទី២ pH=5,3 ថ្ងៃទី៣pH= ប្រហាក់ប្រហែល7។
- កោសិកានៃក្រពេញក្រពះមានលក្ខណៈសាមញ្ញ និងទម្រង់រួមផ្សំនៃក្រពេញក្រពះក៏សាមញ្ញ។
- ការបញ្ចេញរស់ក្រពះដោយកោសិកាក្រពះគ្មានអំពើនៃចិត្តសាស្រ្ត (Spychology) ពេលគឺចំណីអាហារចូលដល់ទើបបញ្ចេញរស់ក្រពះ(Hussaini, 1949)។
- ការរំលាយអាហារមានលក្ខណៈយឺត៖ ត្រីទៅ 3 – 4hត្រីមានលក្ខណៈលឿនជាងសត្វប្រែប្រួលសីតុណ្ហភាព ដ៏ទៃទៀត ប៉ុន្តែយឺតជាង ថនិកសត្វ។ ត្រីស៊ីសាច់ 2-5ថ្ងៃអាស្រ័យដោយសីតុណ្ហភាពទឹកទាប។

– បាតុភូតអង់ស៊ីមរំលាយអាហារប្រហាក់ប្រហែលសត្វកម្រិតខ្ពស់។

❖ គីមីរំលាយអាហាររបស់ពោះវៀន

+ **លំពែង និងរស់រំលាយអាហាររបស់លំពែង៖**

មានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទផ្សេងៗនៃត្រី។ រស់លំពែងមានព៌ណថ្លាមានសារធាតុ Na Carbonat ដែលជាសារធាតុសំខាន់ក្នុងសកម្មភាពអង់ស៊ីមបំបែកខ្លាញ់ Glucid, Protid

ប្រភេទនៃ អង់ស៊ីម មានបីក្រុមសំខាន់ៗ៖

-គឺជា អង់ស៊ីម បំបែក Protid យ៉ាងសំខាន់ក្នុងរស់លំពែង។ Trypsin បានបំបែកចេញពី Trypsinogene(ដោយឯកឯង)ឬអំពើនៃ Enterokinase។ Trypsin មិនសូវមានអំពើលើទម្រង់ Protid ដើម ប៉ុន្តែងាយមានអំពើលើ Protid ដែលបានបំបែកពីទម្រង់ដើម ដោយការចំអិន ឬអាស្រ័យដោយ Gastaric juice (បង្កើត Pepton and almose) ទៅជា AA។ ត្រីដែលគ្មានក្រពះ Trypsin ជាអង់ស៊ីម បំបែក Protid ដែលមាននៅក្នុងពោះវៀន (ពោះវៀនមុខ និងពោះវៀនក្រោយ)។ ដូចនេះ Trypsin មានមុខងារសំខាន់ក្នុងរំលាយអាហារ ចំពោះត្រីដែលគ្មានក្រពះ។

-អង់ស៊ីម **បំបែកសារជាតុស្ករ៖** ក្នុងលំពែងត្រីឆ្អឹងទន់ និងត្រីឆ្អឹងរឹងសុទ្ធតែមាន អង់ស៊ីម Amylase Mantase។ Mantase បម្លែងជា Mantose→Glucose.Glucosidase→Sacharose→ Glucose ។

ជារួម អង់ស៊ីមមានសកម្មភាពទាំងស្រុងក្នុងផ្លូវរំលាយអាហារនៃត្រី។

-**អង់ស៊ីម Lipase:** Lipase ក្នុងរស់លំពែងមាននៅលើត្រីឆ្អឹងទន់ ត្រីឆ្អឹងរឹងមិនមាន Lipase ជាទម្រង់ដើមនោះទេ (Lipase→Glycerol and អាស៊ីតខ្លាញ់)។

-**ប្រម៉ាត់ និងរស់ប្រម៉ាត់៖** ត្រីមួយចំនួនមានប្រម៉ាត់ភ្ជាប់ទៅនឹងថ្លើម មួយចំនួននៅកន្លែងផ្សេងៗគ្នា នោះទម្រង់ផ្សេងៗគ្នា ភាគច្រើនរាងជា Oval, pH នៃប្រម៉ាត់ផ្សេងៗគ្នាទៅតាមប្រភេទត្រី(ដូចជាត្រីបបែល pH=5,4-7,6 អំបូរត្រីកាប 5,5)។ pHនៃពពួកត្រីមានកម្រិតទាប ជាងពពួកសត្វមានសីតុណ្ហភាពមិនប្រែប្រួល។

តាមការស្រាវជ្រាវ ទីKakubrara, 1921កប្រម៉ាត់៖ មានទឹក 79-87%សារជាតុរឹង 12-21% ដែលមាជាតុ Fe, Ca, Mg, K, Cl,H2SO4, H3PO4និងសារជាតុម្សៅ។

តាម Peghen, 1950 ក្រោយពេលកាត់ប្រម៉ាត់ត្រី Leuciscus ឃើញសកម្មភាពពោះវៀនចុះខ្សោយទៅៗ Lipase ថយចុះ ក្រោយមកពីរ បីថ្ងៃត្រីត្រូវស្លាប់ ដោយកើតជំងឺស្បែកលឿង។

-**រស់ពោះវៀន៖** ពោះវៀនផ្នែកមុខមាន Proteinase, Amylase and Lipase អាស្រ័យរស់លំពែងបញ្ចេញ ប៉ុន្តែនៅពោះវៀនក្រោយ Amylase អាស្រ័យដោយកោសិកាពោះវៀនបញ្ចេញ។

H. Vonk កំណត់ថា ពោះវៀនត្រី មិនអាចបញ្ចេញ Amylase ទេ។

តាម Peghen, 1950 បានពិសោធន៍ លើភ្នាសពោះវៀន អាចបញ្ចេញ Amylase and អង់ស៊ីម ដោយ Erepsin ក្រៅពីនេះមាន Lipase Phosphatase ។ មួយចំនួនតិចជា Carbony Polypeptidase, lipeptidase and Tripeptidase…។

## ២.ផ្នែកស្រូបយកសារធាតុចិញ្ចឹម

ការស្រាវជ្រាវអំពីការស្រូបយក ដើម្បីស្វែងយល់ពីចលនានៃសារជាតុចិញ្ចឹមដែលឆ្លងកាត់ ភ្នាសក្រពះ ភ្នាសពោះវៀន ចូលទៅក្នុងឈាម រួចដឹកនាំតាមសរសៃឈាម បញ្ជូនទៅគ្រប់សរីរាង្គ។

### ២.១ ប្រព័ន្ធផ្លូវស្រូបយកសារធាតុចិញ្ចឹម

ផ្លូវស្រូបយកមានពីរ ឈាម និងផ្លូវ Lymph។

**ក/ ផ្លូវ Lymph**

ទំនាក់ទំនងការស្រូបយកសារជាតុខ្លាញ់ម៉ូលេគុលបានត្រូវស្រូបយកចូលទៅក្នុង Blood Vessel Lymph ក្នុងពោះវៀនហើយប្រមូលផ្តុំក្នុងសរសៃវ៉ែននាំចូលទៅក្នុងបេះដូង ដោយមិនឆ្លងកាត់ថ្លើមទេ។

**ខ/ តាមឈាម**

គឺជាផ្លូវស្រូបយកសារជាតុះ ទឹក អំបិលខនិជ ស្ករ និង AA។ ដោយឆ្លងកាត់ថ្លើម ទើបនាំចូលទៅបេះដូង ជារួមសារជាតុឆ្លងកាត់ផ្លូវនេះត្រូវចូលទៅក្នុងថ្លើមទើប នាំទៅគ្រប់ផ្នែកនៃសរីរាង្គ។

### ២.២ កន្លែងស្រូបយកសារធាតុចិញ្ចឹម

ទាំងត្រីទឹកសាបទាំងត្រីសមុទ្រមានអំបិលច្រើនប្រភេទក្នុងខ្លួនក្នុងនោះអំបិលជាច្រើនជាអាហារប្រចាំថ្ងៃចាំបាច់របស់វា។ ទាំងត្រីទឹកសាបនិងត្រីទឹកប្រៃ មានបរិមាណអំបិលប្រហាក់ប្រហែលគ្នានៅក្នុងសារពាង្គកាយ។ ប៉ុន្តែវត្ថុរាវក្នុងសារពាង្គកាយរបស់ត្រីសមុទ្រមិនប្រៃដូចទឹកសមុទ្រដែលវារស់នៅនោះទេ ។ ហេតុនេះហើយត្រីសមុទ្របាត់បង់ទឹកពីក្នុងសារពាង្គកាយជាប្រចាំដោយអូស្មូស នៅក្នុងសូលុយស្យុងមានអំបិលច្រើននៃទឹកសមុទ្រ។ ដើម្បីជំនួសការបាត់បង់ទឹក ត្រីសមុទ្រផឹកទឹកយ៉ាងច្រើន។ ប៉ុន្តែទឹកសមុទ្រផ្ទុក អំបិលច្រើនជាងតំរូវការអំបិលនៃត្រីសមុទ្រ ។ ត្រីទាំងនោះបញ្ចេញចោលអំបិលលើសចំនួនតាមស្រកី និងតាមប្រដាប់រំលាយអាហាររបស់វា។ ត្រីទឹកប្រៃត្រូវការទឹកទាំងអស់ដែលវាបានផឹក ។ ជាលទ្ធផល ត្រីទាំង នោះផលិតទឹកនោមតែបន្តិចបន្តួចប៉ុណ្ណោះ ។

ត្រីទឹកសាបមានបញ្ហាអូស្មូសផ្ទុយពីត្រីទឹកប្រៃ។ សារជាតុរាវក្នុងសារពាង្គកាយរបស់វាប្រៃជាងទឹកសាប។ ជាលទ្ធផល ត្រីស្របយកទឹកឆ្លងកាត់ភ្នាសរបស់វាជាប្រចាំ។ ដូច្នេះ ត្រីទឹកសាបស្របយក

ទឹកយ៉ាងច្រើន ដែលវាមិនចាំបាច់ផឹកឡើយ។ ផ្ទុយទៅវិញ ត្រីទឹកសាបត្រូវតែបញ្ចេញចោលបរិមាណទឹកលើសចំនួន ដែលសារពាង្គកាយរបស់វាស្រូបនោះ។ ជាលទ្ធផល ត្រីទឹកសាបផលិតទឹកនោមយ៉ាងច្រើន។ ត្រីទឹកសាប រក្សាលំនឹងអូស្មូស និងអីយ៉ុងនៅក្នុងជាលិការបស់វាដោយសកម្មភាពស្រូបយកអំបិលតាមស្រកី។ ត្រីដែល ផ្លាស់លំនៅរវាងទឹកសាបនិងទឹកប្រៃ ត្រូវតែអាចតំរូវទៅតាមការផ្លាស់ប្តូរសមាសធាតុអំបិលក្នុងទឹក ។ មាន តែត្រីមួយចំនួនតូចប៉ុណ្ណោះដែលអាចតម្រូវដូចនេះ ។

**ក/ ស្រទាប់ភ្នាសក្រពះ**

ផ្នែកនេះការស្រូបយកមិនខ្លាំងក្លា ដោយការរំលាយអាហារទើបចាប់ផ្តើមកកើត។ ជាពិសេសការស្រូបយកសារជាតុមានទម្រង់ជាខ្លាញ់ ស្ថិតក្នុងក្រពះក្រោម ដូចជាប្រភេទត្រី Cetorhimus, ស្ថិតក្នុង Caecum ដូចជាប្រភេទត្រី salmon ។

**ខ/ ស្រទាប់ភ្នាសពោះវៀន**

ជាកន្លែងសំខាន់ក្នុងការស្រូបយកដោយប្រព្រឹត្តទៅជាបណ្តើរៗចាប់ពីបានដំណើរការបំបែករំលាយចំណីអាហារ។ ទម្រង់រួមផ្សំនៃបំពង់រំលាយអាហារត្រីបញ្ជាក់ពីលទ្ធភាពសបស្រមក្នុងការស្រូបយក។

## ២.៣ ការស្រូបយកសារធាតុចិញ្ចឹម

**ក/ ការស្រូបយក Protein or Acid Amine**

Protid អាចចាប់ផ្តើមស្រូបយកនៅក្នុងក្រពះ ប៉ុន្តែជាសំខាន់ស្ថិតក្នុងពោះវៀន ការស្រូបយកខ្លាំងក្លាបំផុតក្នុងកំណាត់ពោះវៀន (១/៧-១/៥)នៃប្រវែងសរុបពោះវៀន។

ការពិសោធន៍ លើត្រីកាបសាមញ្ញ ការស្រូបយកនូវ Protid ១០០%៖នៅផ្នែកពោះវៀនមុខ ១០% ពោះវៀនកណ្តាល ២៥ – ៣០% ពោះវៀនក្រោយ ៦០-៧០%។

ផ្លូវដែលស្រូបយក Protid តាមផ្លូវឈាមដោយ Protid បានបម្លែងជាAA។

ក្រោយការរំលាយអាហារដែលសមាសធាតុ Protein, AA ច្រើននោះ AA ក្នុងសរសៃវ៉ែននាំចូលក្នុងប្លើមកើនឡើង រួមជាមួយនោះការបញ្ចេញ AA ចូលក្នុង ទឹកមោតកើនឡើង ជាពិសេសសាlycine, Alamine, Cystim, A. Glutamic, Valine, Methyonine, Leusin, Isoleusin, Thryptophan ជាតុមិនចាំបាច់សម្រាប់សរីរាង្គ ល្បឿនក្នុងការស្រូបយកមានលក្ខណៈថយចុះបន្ត តាមលំដាប់ចំពោះ៖ Gl។

ចំណែកការស្រូបយក Protein ក្រោមទម្រង់ជា Tripeptid, Polypeptidនៃត្រីពុំច្បាស់លាស់។

**ខ/ ការស្រូបយកសារជាតុស្ករ(Carbonhydrate)**

សារធាតុ Diglucose & Polyglucose ក្នុងចំណីអាហារបានបម្លែងជា សារធាតុឯក Glucose ដូចជា Glucose, Galactose អាស្រ័យដោយ អង់ស៊ីម រំលាយអាហារ ផលិតផលទាំងនេះការស្រូបយកមានលក្ខណៈងាយស្រួល ព្រមទាំងឈាមបានដឹកនាំយកទៅក្នុងថ្លើម។

### គ/ ការស្រូបយកខ្លាញ់ Lipid

ក្រពះត្រីអាចស្រូបយកមួយចំណែកនៃសារធាតុខ្លាញ់ប៉ុន្តែភាគច្រើនស្ថិតនៅពោះវៀន(ពោះវៀនកណ្តាលច្រើន បន្ទាប់មកពោះវៀនក្រោយ តិចបំផុតពោះវៀនមុខ)។

សារធាតុខ្លាញ់បានស្រូបយកតាមផ្លូវ Lymph សារធាតុខ្លាញ់ទាំងនេះស្ទើរតែបម្លែងជា Monoglycerid ឬ Glycerol & Acide ខ្លាញ់(Glycerid រលាយក្នុងទឹក ខ្លា, Aញ់ រលាយក្នុងរស់ប្រម៉ាត់ បង្កើតជាAacide នៃរស់ប្រម៉ាត់)។ នៃរស់ប្រម៉ាត់ មានមុខងាររស់យ៉ាងសំខាន់ក្នុងការស្រូបយកសារធាតុខ្លាញ់។

អំពើនៃរស់ប្រម៉ាត់ក្នុងរំលាយខ្លាញ់ ធ្វើឱ្យកើនសកម្មភាព Lipase ទី២ Emulsion ខ្លាញ់ និងជំនួយឱ្យការស្រូបយកសារធាតុខ្លាញ់ ជារួមធ្វើការបង្កើត Ester ដែលអាចស្រូបយកបាន។

## ២.៤ បណ្តាកត្តាដែលមានឥទ្ធិពលដល់ការរំលាយអាហារ

### ក/ បរិមាណចំណីអាហារ

បរិមាណចំណីកាន់តែច្រើននោះការរំលាយអាហារត្រូវថយចុះ និងគុណភាពចំណីអាហារ (សារធាតុចិញ្ចឹម) មិនអាចប្រើប្រាស់អស់លទ្ធភាព។ Kadinkin ពិនិត្យកម្រិតរំលាយអាហារត្រី *Perca fluviatilis*

| ចំណីអាហារ | | ការរំលាយសារធាតុ dryភាគរយ | សារធាតុ dry សេសសល់ក្នុងលាមក (10mg ចំណី) |
|---|---|---|---|
| បរិមាណgr | សារធាតុ dry gr | | |
| 4 | 7,48 | 93,6 | 0,63 |
| 8 | 15,04 | 91,1 | 0,89 |
| 16 | 34,04 | 88,5 | 1,15 |

Kanut, 1901 ឱ្យត្រីកាបសាមញ្ញស៊ីចំណីសណ្តែក Lupinus

| កម្រិតចំណី | ការរំលាយក្នុង 100gr Lupinus | | |
|---|---|---|---|
| | Protein | ខ្លាញ់ | Carbonhydrate |
| -ល្មម | 35,2 | 5,4 | 16,8 |
| -ឆ្អែត | 22,1 | 3,6 | 10,4 |
| -ឆ្អែតខ្លាំង | 18,9 | 3,4 | 8,8 |

Knau, 1901 បានសិក្សាលើត្រីកាបសាមញ្ញ ដោយប្រើចំណីសណ្តែក Lupinus ជារួម ការប្រើនូវបរិមាណចំណីអាហារតិច នោះល្បឿននៃការរំលាយអាហាររហ័សជាង និង លំអិតជាង ដោយហេតុ អង់ស៊ីម រំលាយអាហារបានជ្រាបចូលក្នុងចំណីអាហាររហ័ស និង ស្មើជាង។

**ខ/ គុណភាពចំណី**

មានឥទ្ធិពលខ្លាំងក្លាដល់លទ្ធភាពរំលាយអាហាររបស់ត្រីអង់ស៊ីមដោយឥទ្ធិពលសកម្មភាពរបស់រំលាយអាហារ និង មេកានិចពោះវៀន។

Knaut, 1901 ឱ្យត្រីកាបសាមញ្ញស៊ីចំណីផ្សេងៗ

| ប្រភេទចំណី | កម្រិតរំលាយអាហារ % | | |
|---|---|---|---|
| | Protein | lipid | Glucide |
| -Lupinus ស្រស់ | 82-84 | - | 79-82 |
| -Daphnia រស់ | 73-79 | 86-88 | 90-91 |
| -Daphnia ក្រៀម | 69-71 | 84-86 | 88-90 |
| -មេ្យាមី | 86-89 | 91 | 87 |

**គ/ ឥទ្ធិពលនៃសីតុណ្ហភាព**

សីតុណ្ហភាពរបស់មជ្ឈដ្ឋានមានឥទ្ធិពលខ្លាំងក្លាដល់ការរំលាយអាហាររបស់ត្រីនៅពេល TOC កើនឡើងនោះ សកម្មភាព អង់ស៊ីម កើនឡើង នាំឱ្យល្បឿនរំលាយអាហារកើនឡើងដែរ។

| លក្ខណៈនៃចំណីអាហារ | *Rutilus rutilus* | | | កាបសាមញ្ញ | |
|---|---|---|---|---|---|
| | 160C | 190C | 220C | 100C | 210C |
| -សារធាតុ Dry | 73,9 | 79,2 | 72,1 | 77,6 | 81,7 |
| -សារធាតុ Protein | 87,3 | 87,6 | 70 | 81 | 79,3 |

ឃ/ ឥទ្ធិពលនៃអាយុកាល

ក្នុងដំណើរការលូតលាស់ធំធាត់នៃត្រី មានលក្ខណៈសមាមាត្រទៅតាមការរំលាយអាហារៈ ត្រីកាន់តែធំនោះការរំលាយអាហារកាន់តែលឿន និង Emulsion ជាងត្រីតូច។ លោក Kadinkin ពិនិត្យតាមដានកម្រិតរំលាយអាហាររបស់ត្រីSturgeon (Acipencer Acipencer L)

| អាយុត្រីចាប់ពីពេលម្ចាស់ការស៊ីចំណី (ថ្ងៃ) | ទម្ងន់ជាមធ្យមរបស់ត្រីgr | រំលាយអាហារ % | |
|---|---|---|---|
| | | សារធាតុDry | សារធាតុផ្ទុក N |
| 11-21 | 0,738 | 63,4 | 86,6 |
| 21-31 | 1,215 | 88,7 | 92,5 |
| 31-36 | 2,335 | 94,9 | 95,5 |
| 73-79 | 17,078 | 95 | 96 |

ដំណើរការរំលាយអាហារ អាស្រ័យដោយអាយុកាលជា Complexដោយមូលហេតុៈ អង់ស៊ីមរំលាយអាហារមានគ្រប់គ្រាន់អំពី បរិមាណ និង សមាសភាពគុណភាព ដែលជាហេតុធ្វើឱ្យការរំលាយអាហាររហ័ស និង Emulsion ជាង។

# មេរៀនទី៦
# សរីរបម្លែងសារធាតុនិងថាមពល

បម្លែងសារធាតុ ជាលក្ខណៈមូលដ្ឋានរបស់សរីរាង្គរស់ និងជាកត្តាកំណត់សរីរាង្គរស់ ឬស្លាប់។

បម្លែងសារធាតុមានដំណើរការពីរៈ សមានកម្ម និងអសមានកម្ម ក្នុងដំណើរការនេះមានដំណាក់កាលពីរគឺ បំបែក និង ប្រមូលផ្សំ (សមាសភាពនៅក្នុងសារធាតុចិញ្ចឹម) នាំឱ្យប្រែប្រួលដោយ ការបង្កើតថាមពល ឬប្រើប្រាស់ថាមពលដែរ។

## ១. ការបម្លែងសារធាតុ

### ១.១ បម្លែង Protid

**Protid:** ជាសមាសភាពសំខាន់បំផុតរបស់សរីរាង្គរស់មានប្រហែល ១៦-១៨% នៃទម្ងន់របស់សរីរាង្គ។

Protein ក្នុងចំណីអាហារក្រោយពេលបំបែកត្រូវបានសរីរាង្គស្រូបយកទៅក្នុងឈាមក្រោមទម្រង់ជា រួចចូលទៅក្នុងថ្លើ ថ្លើមយកមួយផ្នែកតិចបង្កើតបានជា AA បំពេញឱ្យក្នុងប្លាស្មា ចំណែកផ្សេងទៀតដឹកនាំទៅគ្រប់ផ្នែកនៃសរីរាង្គ មួយចំណែកត្រូវបង្កើតជា Protis ថ្មីជំនួសឱ្យ Protid ចាស់សរីរាង្គដែលបានបម្លែង។

សត្វដែលលូតលាស់ពេញលក្ខណៈ ជានិច្ចជាកាល Protid ដែលជំនួសមានសមាមាត្រផ្សេងៗគ្នាមួយផ្នែកទៀត បម្លែងជា Protid ផ្សេងរួមមាន៖ creatinine, Cholin ឬ Melamin រួចបង្កើតជាសារជាតុរំញោច ដូចជា Insulim, Adrenalin, Thyroxin...។ AA មួយចំនួនបម្លែងជា Glucogenនិងខ្លាញ់ក្នុងសារពាង្គកាយក្រៅពីនេះនៅមានចំណែកខ្លះ អុកស៊ីតកម្មបង្កើតជា កាបូនឌីអុកស៊ីត និងទឹក រួមជាមួយសមាសជាតុដែលមានផ្ទុក Nitrogen and Acide Keto (សារជាតុបាត់ Protein) $NH_3$ បានបង្កើតជា អុយរ៉េ ឆ្លងកាត់តម្រងនោមបញ្ចេញមកក្រៅ។

Acide Keto មួយផ្នែកបម្លែងជា ស្ករ មួយផ្នែករួមជាមួយខ្នែង Amine ($NH_2$) បង្កើតជាប្រភេទ Acide Amine ផ្សេង។

ក្រៅពី ស្ករ និងខ្លាញ់ Protidក្នុងសរីរាង្គមិនមានឥទ្ធិពលត្រៀមបម្រុងទុកនិងបម្រុងផ្ទុកជាកំណត់បានឡើយ។ ក្នុងចំណីអាហារប្រភេទខ្លះមានគ្រប់ប្រភេទអាស៊ីត Amine ចាំបាច់ដែលសរីរាង្គមិនអាចប្រមូលបាន ប៉ុន្តែក៏មានប្រភេទចំណីអាហារខ្លះមិនមានគ្រប់ប្រភេទ AA ចាំបាច់ឡើយ។

គេអាចកំណត់ថាបណ្តាប្រភេទ AA នេះ គឺជារបបកំណត់ដ៏សំខាន់ក្នុងការវាយតម្លៃគុណភាពចំណីអាហារដែលមានផ្ទុក Protid ។ Protid មានអត្ថន័យ យ៉ាងជ្រាលជ្រៅជាមួយសរីរាង្គ វាជាវត្ថុធាតុ

ដើមចាំបាច់ដើម្បីបង្កើតគ្រឿងសរីរាង្គ អាចកំណត់ថា ជាដំណើរការលូតលាស់សារពាង្គកាយ និងដំណើរការប្រមូលផ្តុំបង្កើត Protid ថ្មីក្នុងសរីរាង្គ។

ដំណើរការអេសមានកម្ម Protid ក្នុងសរីរាង្គត្រីមិនទាន់បានស្វែងយល់ជាពិតប្រាកដ ប៉ុន្តែបណ្តាលសាជាតុជាចុងបញ្ចប់ របស់ដំណើរការបម្លែងសារធាតុ protid ចំពោះបណ្តាប្រភេទត្រីនោះមានលក្ខណៈផ្សេងគ្នា៖

-ត្រីឆ្អឹងទន់ជាសំខាន់គឺ អុយរ៉េ

-ត្រីឆ្អឹងរឹងទឹកសាប ផ្នែកសំខាន់ជា Amoniac និងមួយផ្នែកតិច ជាអុយរ៉េ

-ត្រីឆ្អឹងរឹងទឹកប្រៃគឺ Amoni & Trimethyl Amine oxyd

**ក/ កត្តាមួយចំនួនមានឥទ្ធិពលដល់ការបម្លែង Protid របស់ត្រី**

❖ **តម្រូវការ Protein ក្នុងចំណីអាហាររបស់ត្រីថយចុះទៅតាមអាយុត្រី**

ត្រីនៅតូចត្រូវការ Protid ច្រើនជាងត្រីពេញវ័យ។

ផ្អែកលើឯកសារមួយចំនួន ត្រីកបសាមញ្ញ 1⁺ ត្រូវការ protein 1/3 នៃបរិមាណចំណីអាហារចាំបាច់ ប៉ុន្តែត្រី 2⁺ ក្នុងចំណីអាហារម្សៅមី 100gr ត្រូវការលាយបញ្ចូល Protein 13,5 gr តែប៉ុណ្ណោះ និងក្នុងដំណាក់កាលបន្តពូជនោះកាន់តែមានបរិមាណតិចទៅទៀត។

❖ **ត្រីនៅពេលបំលាស់ទីបន្តពូជ**

ដូចជាត្រី Salmon សារធាតុចាំបាច់ដើម្បីបង្កើតកោសិកាបន្តពូជ ថាមពលសម្រាប់ធ្វើចលនាគឺ protein។

Protamin គឺជា Protd ថ្មីដែលទើបបង្កើតថ្មី ជំនួស protid ចាស់ដែលបាត់បង់ក្នុងពេលបំលាស់ទីបន្តពូជ និង អត់ចំណីអាហារយូរថ្ងៃ។

❖ **បរិមាណ និងគុណភាព Protein**

ក្នុងចំណីអាហារផ្សេងគ្នា នោះការប្រមូលផ្តុំ Protein ក្នុងសារពាង្គកាយផ្សេងគ្នាដែរ ជាពិសេស AA មួយចំនួនដែលត្រីមិនអាចសំយោគបានមាន៖ Lidin, Thryptophan, Histidin... ដែលកកើតក្នុងសរីរាង្គដោយសារក្នុងចំណីអាហារមានផ្ទុកសារធាតុទាំងនេះ។

ដូចនេះទោះជាចំណីអាហារសម្បូរ ប៉ុន្តែនៅខ្វះបណ្តា AA ទាំងនោះត្រីអាចរស់នៅក្នុងរយៈពេលកំណត់ និងត្រូវរងនូវការខ្វះខាត Vitamin ឬជីវជាតិ រួចមកមុខងារសរីរាង្គមួយចំនួនបាត់បង់ជាចុងបញ្ចប់ត្រីត្រូវស្លាប់។

❖ **មជ្ឈដ្ឋានមានអំពើដល់ការបម្លែង protid របស់ត្រី**

តាមអ្នកស្រាវជ្រាវសូវៀត pH ទឹកសាបនោះ ដំណើរការសមានកម្ម Protid របស់ត្រីកាបសាមញ្ញថយចុះ

Ex: pH=5,5 ទោះបីឱ្យត្រីស៊ីចំណីមាន Protid តិចតួច ប៉ុន្តែជាលទ្ធផលដែលបញ្ចេញចោលមានផ្ទុក N ច្រើននេះ បញ្ជាក់ថា ការស្រូបយក Prottid ត្រូវបាត់បង់មុខងារ។

**ខ/ លំនឹងអាសូត(Nitrogen)ឬលំនឹង Protein**

មេគុណរវាង Protein ក្នុងចំណីអាហារនិងបរិមាណ protein បញ្ចេញមកក្រៅក្នុងមួយថ្ងៃដោយស្មើ១។

តាមលំនឹងអាសូតត្រូវកំណត់តាម៖ $K = \frac{\mathrm{N}}{\mathrm{n+n1}}$

N ជាបរិមាណ N(អាសូត) ពីចំណីអាហារផ្ដល់ឱ្យ(បានស្រូបយក)

n ជាបរិមាណN(អាសូត) ដែលសរីរាង្គមិនបានស្រូបយក

n`ជាបរិមាណ N(អាសូត) ត្រូវបានបញ្ចេញមកក្រៅ

ក្នុងករណី K=1 នោះN(អាសូត)=n+n` ហៅថាលំនឹងស្មើកកើតចំពោះសរីរាង្គដែលមិនលូតលាស់

K>1 នោះ N>n+n` ហៅថាលំនឹងវិជ្ជមានកកើតចំពោះសរីរាង្គកំពុងលូតលាស់ធំធាត់។

K<1 នោះ N<n+n`ហៅថាលំនឹង អវិជ្ជមានកកើតលើសរីរាង្គ ចាស់ជរា ឈឺ ខ្វះសារជាតុចិញ្ចឹម(ជីវជាតិ) ឬការអត់ឃ្លានជាយូរថ្ងៃ។

១.២ បម្លែងសារជាតុខ្លាញ់

